# ទន្សាយ

សំដែងអំពីស្ពានសួគ៌



ព.ស.២៤៩៤ គ.ស.១៩៥១

LIBRARY

២៥៦.
២៤

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

# ទន្សាយ

សំដែងអំពីស្ដាគស្លូត៍



ព.ស.២៤៩៤ គ.ស.១៩៥១

www.budinst.gov.kh www.elibraryofcambodia.org

# សត្តកថា

សំដែងអំពីស្ថានសួគ៌

បោះពុម្ពលើកទី១

ព.ស.២៤៩៤ គ.ស.១៩៥១

ផ្ទះលេខ ៩៧ វិថីហាង់រីរុស្សៀយេ

www.budinst.gov.kh www.elibraryofcambodia.org

# បណ្ណាគារប៉ោ-ហ៊ាត

ផ្ទះលេខ ៩៧ វិថីហាក់រីរុស្ស៊ីយេ

ខាងត្បូងបន្ទាយទាហានខេមរភូមិន្ទ ភ្នំពេញ

សៀវភៅដែលបោះពុម្ពរួចហើយផ្សាយចេញគឺ:

បទានុក្រមធម្មបទទី ១

អរិដ្ឋា កថា

សុភាសិតសង្គ្រោះពាក្យកាព្យ

អនុពុទ្ធប្រវត្តិ

សង្គីតិប្រវត្តិ

ទុល្លភធម៌

ធម្មវិភាគទី ២

ប្រវត្តិនាងបដាចារពាក្យកាព្យ

និរយ កថា

គវ៌រកោវាទ

ភេសជ្ជៈក្ខន្ធកៈ

មានតទៅទៀត

www.budinst.gov.kh www.elibraryofcambodia.org

២៥៦.២៤

# សត្តកថា

សំដែងអំពីស្ថានសួគ៌

ព្រះមហា នូម-ណាគ្រី

ប្រែ រៀបរៀង

ព្រះវិភទញ្ញាណ (កៅ-ស៊ុម)

សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់

រៀងផ្ទុំតសម្រួល

បោះពុម្ពលើកទី ១

ព្រះរាជបណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៤៥៨៧/៥៥

អ្នករក្សាសិទ្ធិ

ចៅកែ ប៉ោ-ហ៊ិត

ធ្វើជំនូញនៅក្រុងភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

" សគ្គកថា " នេះ ជាច្បាប់សំដែងប្រាប់អំពីរឿងស្ថានសួគ៌ សេចក្ដីសុខសម្រាន្ដក្សានសប្បាយរបស់អ្នកនៅក្នុងស្ថានសួគ៌ ដែលជាផលបុណ្យគុណសំណាង ដែលគេសាងកាលជាតិជាមនុស្ស លុះទម្លុះកាយទម្លាយខន្ធ ក៏នឹងបានទៅកាន់គំណើតកើតក្នុងស្ថានសួគ៌ រមែងបានសុខកាយសប្បាយចិត្ត សោយទិព្វសម្បត្តិសម្បូណ៌សុខជាងមនុស្ស ។

ស្ថានសួគ៌នេះ បើតាមដំណឹងដែលមានមកក្នុងផ្លូវព្រះពុទ្ធសាសនាថាជាស្ថានវិសេសមួយប្លែកអំពីស្ថាននានា ដែលមាននៅក្នុងមនុស្សលោក ពួកមនុស្សជាបុថុជ្ជនទាំងឡាយពុំអាចទៅឃើញផ្ទាល់ភ្នែកបានឡើយ មានតែព្រះអរិយបុគ្គលដែលចេះដឹងនូវចិត្តសាស្ត្រ ជាអ្នកមានឫទ្ធិទើបទៅឃើញផ្ទាល់ភ្នែកបាន ។ ក្នុងពុទ្ធកាល មានដំណាលថា សម័យថ្ងៃមួយព្រះមោគ្គល្លានត្ថេរដែលជាអ្នកមានឫទ្ធិច្រើន បានសូមពុទ្ធានុញ្ញាតហើយចូលឈានទៅមើលស្ថាននរក ត្រឡប់ពីស្ថាននរកទៅមើលស្ថានសួគ៌ទៀត បានពិនិត្យមើលនូវស្ថានភាពទឹកដី



www.budinst.gov.kh www.elibraryofcambodia.org

វិមានប្រាសាទ លក្ខណៈសម្បត្តិ រូបសម្បត្តិ ភាពអនាម័យនិងជីវភាព របស់ស្ថានទាំងនោះដោយសព្វគ្រប់ ក៏ត្រឡប់មកស្ថានមនុស្សវិញ បានប្រកាសផ្សាយពត៌មាននេះប្រាប់ដល់ពួកមនុស្សទាំងឡាយដែលនៅក្នុងសកលនិគមជនបទទាំងពួង ក្នុងពេលនោះពួកមនុស្សទាំងឡាយក៏បានដឹងបានស្គាល់ថាមានស្ថាននរកនិងស្ថានសួគ៌ដោយជាក់ច្បាស់ ៗ

ព្រោះហេតុដែលខ្ញុំបានឃើញរឿងរ៉ាវយ៉ាងនេះហើយ បានជាខ្ញុំរាវរកគម្ពីរដីកាក្បួនច្បាប់ ដែលមាននិយាយពីស្ថាននរកនិងស្ថានសួគ៌មករៀបរៀងជាសៀវភៅ ដើម្បីជាប្រយោជន៍ដល់សិក្សាកាមនិករទាំងឡាយទូទៅ ។ សៀវភៅនេះខ្ញុំរៀបរៀងជាពីរច្បាប់គឺ ១ – និយាយពីស្ថាននរក ខ្ញុំឲ្យឈ្មោះថានិរយកថា ២ – និយាយពីស្ថានសួគ៌ខ្ញុំឲ្យឈ្មោះថា “ សគ្គកថា ” លុះរៀបរៀងចប់ហើយខ្ញុំបានប្រគល់សៀវភៅទាំងពីរច្បាប់នេះ ឲ្យសិទ្ធិផ្ដាច់ទៅឋៅកែ ប៉ោ ហ៊ត ដើម្បីចាត់ការបោះពុម្ពផ្សាយទូទៅក្នុងសកលកម្ពុជរដ្ឋ ៗ ដោយវិរិយភាពរបស់ខ្ញុំនេះ

សូមសន្តិសុខចូរមានដល់សកលលោក!

សូមជ័យជោគយោគយិតយោងកម្ពុជា!

សូមរលាយពាយរលត់បាត់ផវា!

សូមបភាពុទ្ធសាសន៍រុងរឿងយើយ!

ថ្ងៃទី ៧ មិថុនា ឆ្នាំ ១៩៥១

ព្រះមហា ឱម - ណាគ្រី

នៅភូមិផ្លាធំ ឃុំស្វាយពោ ស្រុកសង្កែ

ខែត្របាត់ដំបង

www.budinst.gov.kh www.elibraryofcambodia.org

# បរេទនកថា

សៀវភៅ " សគ្គកថា " នេះ ខ្ញុំបានទទួលពីព្រះមហាឧម - ណាគ្រី ហើយបានប្រគេនដល់ព្រះតេជព្រះគុណ ព្រះវិរទ្ធញាណ "កោ ស៊ុម" សូមឲ្យលោកជួយពិនិត្យថែមទៀត លោកក៏ព្រមទទួលពិនិត្យដោយសេចក្ដីមេត្តាចំពោះរូបខ្ញុំ ។

ក៏ការពិនិត្យសៀវភៅនេះ ឃើញមានសម្រួលពាក្យពេចន៍ខ្លះ ដកចេញខ្លះ បំពោះពាក្យណាដែលជាទំនាស់ បន្ថែមពាក្យបំពេញសេចក្ដីនឹងដាក់នយលក្ខណ ថែមខ្លះ សូមលោក ឧម-ណាគ្រី អភ័យទោសដល់ខ្ញុំ ដែលប្រាថ្នាឲ្យត្រឹមត្រូវល្អឡើងដោយមេត្រីភាពចំពោះរូបលោក ខ្ញុំបាទមានសេចក្ដីត្រេកអរចំពោះលោកដែលបានឲ្យសៀវភៅ "សគ្គកថា" នេះមកខ្ញុំជាអនេក សូមឲ្យលោកបានប្រកបដោយសេចក្ដីសុខ បរិវេនក្នុងក្រុមគ្រួសាររបស់លោកទាំងបច្ចុប្បន្ននឹងបរលោកកុំបីឃ្លាតឡើយ ។

*សួស្ដីប្រទេសកម្ពុជា, សួស្ដីព្រះពុទ្ធសាសនា, សួស្ដីព្រះមហាក្សត្រ,*

ប៉ៅកែ ញ៉ោ - ហ៊ត

# សត្ថកថា

### សំដែងអំពីឋានសួគ៌

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ឋានសួគ៌គួរប្រាថ្នា

ពាក្យថា "សួគ៌" ជាស្ថានដែលជាទីចូលចិត្តនៃពុទ្ធសាសនិកជនទូទៅហើយថា ជាទីមានសេចក្ដីសុខសប្បាយច្រើន ដោយបានធ្លាប់ស្ដាប់លោកសំដែងខ្លះ បានអានសៀវភៅព្រះពុទ្ធសាសនាខ្លះ តែមិនមានសាមញ្ញជនណាមួយឃើញបានដោយខ្លួនឯងឡើយ មានតែវិសេសៈជនជំនាន់មុនប៉ុណ្ណោះទើបឃើញបាន ដោយហេតុនេះ សេចក្ដីដឹងប្រវត្តិឋានសួគ៌របស់សាមញ្ញជន គួរហៅថា សេចក្ដីដឹងតាម គឺដឹងតតំណមកពីបានឮបានស្ដាប់ប៉ុណ្ណោះ មិនមែនជាសេចក្ដីដឹងជាក់ច្បាស់ដោយខ្លួនឯង ដោយហេតុនេះ នឹងសូមអធិប្បាយពាក្យថា "សួគ៌" តាមសព្ទដើម ល្មមឲ្យជាគ្រឿងគិតពិនិត្យពិចារណារបស់អ្នកត្រូវការចង់ដឹងរឿងឋានសួគ៌ ទុកដោយសង្ខេបដូចតទៅនេះ

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យថា "ស្ថគ៌" សព្ទដើមជាភាសាមគធៈថា "សគ្គ" សព្ទនេះបំបែកចែកចេញជាពីរពាក្យគឺស ១ គ្គ ១ ។ ស សព្ទដើមជា "សុ" ប្រែថា "ល្អ ស្អាតងាយ" គ្គ សព្ទដើមជា អគ្គៈ ប្រែថាចុងកំពូល លើស" រួមជាសគ្គ ប្រែថា "ល្អ" លើស ស្អាត លើស ងាយលើស" ។

សំដៅសេចក្តីថា ល្អលើសក្នុងផ្លូវលោក គឺល្អក្នុងផ្លូវរូប សំឡេងក្លិនរស សម្ផស្ស ទ្រព្យ យស សុខ សរសើរ អាយុ វណ្ណៈ ជាដើម តាមលោកនិយម ។ ស្អាតលើសក្នុងផ្លូវលោក គឺស្អាតក្នុងរូប សំឡេង ក្លិនជាដើម ។ ងាយលើសក្នុងលោក គឺងាយស្រួលការចង់បានអ្វីក៏បានងាយ ៗ សមតាមបំណងប៉ង ប្រាថ្នា ។

ពួកដែលនៅក្នុងឋានស្ថគ៌ សុទ្ធតែមានសេចក្តីសុខសម្រាន្ត ក្សាន្តសប្បាយដ៏លើសលប់ជាជាន់ៗ ទៅទាំងអស់ គឺអ្វីៗ សុទ្ធតែ ល្អលើស ស្អាតលើស ងាយលើសជាទីភ្លើតភ្លើនចំរើនចិត្តឥត ខ្វះខាតដូចរូបក៏ស្រស់បស់ស្អាតបាត ស្រួលបួល ល្អល្អះត្រចះ

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់ផ្លូវផង់រុងរឿង សមរម្យ ឆោមឆាយ ឆើតស្មើត ប្រិមប្រិយ ព្រោងព្រាយ ពណ្ណរាយ ល្អទាំងព្រម សំឡេងក៏ពិរោះ ផ្អែមល្ហែមគួរចង់ស្ដាប់ ក្លិនក៏ក្រអូបក្រអៃបឈ្ងុយឈ្ងប់ឆ្ងាញ់ រសក៏មានឱជាជាប់វិញ្ញាណ, សម្ផស្សក៏ទន់ល្មន់ល្មួត រលីងរលង់ រលើបក្នុងប៉ះពាល់, អ្វីៗ គ្រប់យ៉ាង សុទ្ធតែល្អលើស ស្អាតលើសជាងរបស់មនុស្សទាំងអស់ ទាំងរយទាំងពាន់ដង ។

អ្នកដែលនៅក្នុងឋានសួគ៌ជាន់នោះៗ ពីដើមកាលនៅជាមនុស្ស សុទ្ធតែជាអ្នកប្រព្រឹត្តល្អប្រពៃ មានហិរិ សេចក្ដីអៀនខ្មាសចិត្តខ្លួនឯង មិនហ៊ានបំពានធ្វើអំពើអាក្រក់ នឹងឱត្តប្បសេចក្ដីខ្លាចរអា រអើមខ្ពើម បំពោះផលរបស់សេចក្ដីអាក្រក់ ហើយមិនធ្វើសេចក្ដីអាក្រក់ដោយកាយវាចា ធ្វើតែអំពើល្អស្អាត កាលស្លាប់ចាកមនុស្សហើយ ទើបបានឡើងទៅកើតក្នុងឋានសួគ៌ ។

សូមគិតមើលថា ផលរបស់ធម៌ទាំង ២ ខនេះ ជាយ៉ាងណា! ក្នុងវេលាដែលយើងនៅជាមនុស្ស កាលបើពិនិត្យមើល

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យជាក់ច្បាស់លាស់ទៅ នឹងឃើញថា ផលរបស់ធម៌ទាំង ២ ១ នេះ គឺឲ្យបានសេចក្ដីត្រជាក់ចិត្ត សេចក្ដីសុខចិត្ត បើអ្នកណាមានធម៌ទាំង ២ ១ នេះ ប្រចាំនៅក្នុងចិត្តជាប់ហើយ អាចរាប់បានថា សរជននោះទោះទៅនៅក្នុងឋានសួគ៌ជាន់មនុស្សក៏មានរូបរាងល្អស្អាតលើស គឺល្មមជាទីពេញចិត្ត សមគំនិត គួរអង្គុយជិតជល់អ្នកសេពគប់, សំឡេងរបស់អ្នកនោះ ក៏ជាសំឡេងពិរោះ មិនត្រគោះបោះបោក មិនទ្រាន់ដល់អ្នកស្ដាប់, ក្លិនរបស់អ្នកនោះ ក៏ក្រអូបលើស គឺក្រអូបប្រាសខ្យល់ នាំឲ្យជនទាំងឡាយចង់ចូលទៅអង្គុយជិត (សំដៅក្លិនគឺសីល) ធ្វើឲ្យអ្នកលាបផឹកត្រជាក់បែះដូង ត្រជាក់ចិត្ត សម្ផស្សអ្នកនោះក៏ជាសម្ផស្សល្អលើស ធ្វើឲ្យអ្នកគប់សមាគមបានសេចក្ដីសុខចិត្ត (សំដៅសម្ផស្សគឺការគប់រក) រួមសេចក្ដីថា អ្នកដែលមាន ហិរិ ឱត្តប្បៈ ប្រចាំនៅក្នុងចិត្តហើយ តែងមានសេចក្ដីសុខចិត្ត ត្រជាក់ចិត្ត រីករាយចិត្ត ថ្លាចិត្ត ផ្អែតចិត្ត រាប់ថាៈបានទៅនៅស្ថានសួគ៌ដោយចិត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

តាមដែលថ្លែងមកនេះ សូមឲ្យលោកអ្នកពិនិត្យមើលចុះថា កាលបើមានសេចក្ដីល្អប្រចាំនៅក្នុងចិត្តដូច្នេះហើយ នឹងមានសេចក្ដីសុខឬទេ? បើនៅមិនឃើញថាមានសេចក្ដីសុខទេ សូមឲ្យគិតល្អិតបន្តិចទៅទៀត គឺឲ្យធៀបខ្លួនយើងដែលធ្វើសេចក្ដីល្អ នឹងអ្នកដែលធ្វើសេចក្ដីអាក្រក់ ខាងណាបានសុខទុក្ខផ្សេងគ្នាយ៉ាងណា? កាលបើពិនិត្យសង្កេតដូចនេះហើយ នឹងឃើញថាអ្នកដែលធ្វើអាក្រក់ ត្រូវទុក្ខចិត្ត ក្ដៅចិត្ត រាប់ថាបានធ្លាក់នរកទាំងរស់ ចំណែកខាងអ្នកធ្វើល្អ រមែងមានសេចក្ដីសុខកាយសប្បាយចិត្ត ត្រជាក់ចិត្តជានិរាប រាប់ថាបានស្ថានសួគ៌ទាំងរស់ ។

ម្យ៉ាងទៀត សូមធៀបសេចក្ដីសុខរបស់មនុស្សជាន់ទាប នឹងជាន់ខ្ពស់ឲ្យជាគូគ្នា គឺឲ្យធៀបខ្លួនយើងនឹងព្រះរាជាព្រះអគ្គមហេសី ព្រះរាជោរស ព្រះរាជធីតា ដែលលោកលើកដំកើងថាជាសម្មតិទេព តើខាងណាបានសុខច្រើនជាង? ទីនៅ អាហារ សំលៀកបំពាក់ ថ្នាំកែរោគ របស់លោកទាំងនោះនឹងរបស់យើង ខាងណាថ្លៃជាង? កាលធៀបមើលដូច្នេះ នឹងឃើញបានថា

សេចក្តីសុខរបស់មនុស្ស រមែងច្រើនជាងគ្នាជាជាន់ៗ ទៅហើយ បំណាច់បើសុខរបស់មនុស្សនឹងសុខក្នុងសួគ៌ នឹងឃើញឆ្ងាយគ្នាលន្លឹមលន្លោចយ៉ាងម៉ិចទៅហ្ន៎ ៗ នេះ ព្រះពុទ្ធជាម្ចាស់បានទ្រង់ត្រាស់សំដែងទឹងនាងវិសាខាក្នុងឧបោសថសូត្រថា "បើធៀបសុខរបស់មនុស្សនឹងសុខក្នុងស្ថានសួគ៌ ឃើញថាសុខរបស់មនុស្សមានប្រមាណតិចណាស់ ដូចយ៉ាងអាយុ ក៏ឆ្ងាយគ្នាជាច្រើន គឺអាយុក្នុងស្ថានសួគ៌ក្នុងចាតុម្មហារាជិកា ៥០០ ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្សបាន ៩ លានឆ្នាំ ៥០ ឆ្នាំក្នុងមនុស្សជា ២៤ ម៉ោងក្នុងស្ថានសួគ៌ជាន់ចាតុម្មហារាជិកា ដូចនេះជាដើម ។

បើនឹងធៀបដោយវណ្ណៈ គឺពណ៌សម្បុរកាយនឹងសម្បុរគ្រឿងប្រដាប់ប្រដារបស់មនុស្សនឹងទេវតា ក៏ខុសឆ្ងាយ ពណ៌របស់មនុស្សមិនអាចកំចាត់បំបាត់ងងឹតឲ្យភ្លឺស្វាងបាន មានភ្លឺបន្តិចបន្តួចខ្លះៗ ក៏ចំពោះរបស់គ្រឿងប្រដាប់ ដែលធ្វើអំពីពេជ្រចំណែកពណ៌សម្បុររបស់ទេវតា ទើបអាចធ្វើទីដែលងងឹតឲ្យភ្លឺ

www.budinst.gov.kh www.elibraryofcambodia.org

ស្វាងបាន មានរស្មីផ្សាយទៅបាន ២ យោជន៍ ឬដែលប្រាកដក្នុងខាងដើមនៃព្រះសូត្រផ្សេង ៗ ដែលពោលដល់ទេពតា ចូលគាល់ព្រះពុទ្ធជាម្ចាស់ ក្នុងមជ្ឈិមយាមរាត្រីថា ទេពតាញុំាងព្រះជេតពនវិហារទាំងអស់ ឲ្យភ្លឺស្វាងដោយពណ៌នៃរាងកាយ និងគ្រឿងប្រដាប់របស់ទេពតាទាំងនោះ ចំណែកសុខ កំឡាំងនិងអ្វីៗដទៃ ៗ ទៀត របស់មនុស្សនិងទេពតា ក៏គ្រោតគ្រោតនិងប្រណីតជាងគ្នាជាទីបំផុត ។

ពាក្យថាទេពតា

ពាក្យថា " ទេពតា " នេះ ជាពាក្យដែលមានអ្នកចូលចិត្តទៅហើយថា សំដៅយកអ្នកមានសេចក្ដីសុខសប្បាយយ៉ាងលើស គឺជាអ្នកសោយទិព្វសម្បត្តិនៅក្នុងស្ថានសួគ៌ តែមិនសូវមាននរណាគិតថា ពាក្យនេះ ប្រែថា យ៉ាងណា និងពាក្យថា ទេពតា ឬ ទេវតាមានប៉ុន្មានពួក ៗ ណានៅទីណា ព្រោះដោយច្រើនចូលចិត្តថា មានតែមួយពួក នៅតែមួយកន្លែង គឺនៅក្នុងស្ថានសួគ៌ប៉ុណ្ណោះ សេចក្ដីចូលចិត្តនេះ

www.budinst.gov.kh www.elibraryofcambodia.org

រាប់ថាទៅខ្លះ ដោយហេតុនេះ ខ្ញុំសូមបំពេញសេចក្ដីប្ដូលចិត្ត របស់អ្នកដែលនៅប្ដូលចិត្តខ្លះ ឬរាក់ឲ្យទូលាយឡើង តាមលក្ខណៈផ្សេង ៗ ដូចតទៅនេះ

ពាក្យនេះ ប្រែតាមសេចក្ដីសំដៅរបស់សព្ទដើម ៨ យ៉ាង គឺសព្ទដើមថា "ទេវ" ផ្លាស់មកអំពី "ទិវ" ក្នុងគម្ពីរសទ្ទនីតិពោលទុកថា: "កិឡា វិជិគំ សាព្យវហារជុតិ ថុតិ កន្តិ គតិ សត្តិសូតិ ទិវុធាតុ វត្តតិ" ប្រែថា "ទិវុធាតុ សំដៅសេចក្ដីថា លេង ត្រូវការឈ្នះ និយាយរុងរឿង សរសើរ ចង់ ទៅអាច ។

លោកកំចាយសព្ទទាំង ៨ នេះ ចេញទៅថា:

១- កីឡតិ កីឡតា ការលេងឈ្មោះថា កិឡា ។

២- វិជិគីសតិ វិជយិតា ការប្រាថ្នាឈ្នះឈ្មោះថាវិជិគីសា

៣- ព្យវហារតិ វោហារោ ការនិយាយឈ្មោះថា ព្យវហា ។

៤- ជុតីតិ សោភា សេចក្ដីល្អ ឈ្មោះថាជុតិ គឺរុងរឿង

៥- ថុតីតិ ថោមតា ការសរសើរឈ្មោះថា ថុតិ ។

www.budinst.gov.kh www.elibraryofcambodia.org

៦- កត្តីតិ កមនីយតោ ការមានអ្នកចង់ឈ្មោះថា ចង់

៧- គតីតិ គមនំ ការទៅឈ្មោះថាគតិ

៨- សត្តីតិ សាមត្ថិយំ ការមានសេចក្ដីអាចឈ្មោះថាសត្តិ

ក្នុងសេចក្ដីសំដៅទាំង ៨ យ៉ាងនេះ ប្រការទី ១ គឺពាក្យ "លេង" សំដៅចំពោះសម្មតិទេវតាប៉ុណ្ណោះ បំណែកវិសុទ្ធិទេវតា នឹងឧបត្តិទេវតា សមគួរដល់សេចក្ដីសំដៅទាំង ៨ យ៉ាងនោះ ។ មានបទវិគ្រោះដូចតទៅនេះ

១- ទិព្វន្តិ កីឡន្តិ អត្តនោ វិសយេ ឥស្សរិយំ ករោន្តីតិ ទេវា រាជានោ អ្នកដែលលេង គឺរមែងប្រើភាពជាធំត្រូវតាមនាទីរបស់ខ្លួន ហៅថាទេវតា បានដល់ព្រះរាជា ។

ទិព្វន្តិ កីឡន្តិ បញ្ចហិ កាមគុណេហីតិ ទេវា ចាតុម្មហារាជិកាទយោ អ្នកដែលលេងដោយកាមគុណ៥ ហៅថាទេវតា បានដល់ទេវតាជាន់ចាតុម្មហារាជិកាជាដើម ។

២- បដិបក្ខេ វិជេតុំ ឥច្ឆន្តីតិ ទេវា ។ល។ អ្នកដែលត្រូវការដើម្បីឈ្នះ បដិបក្ស ហៅថា ទេវតាមាន ។ល។

www.budinst.gov.kh www.elibraryofcambodia.org

៣ លោកស្ស យុត្តាយុត្តំ ភោហរន្តីតិ ទេវា ។ល។ អ្នកដែលពោលពាក្យតាមឃើញថាគួរ ឬមិនគួរយ៉ាងណា ដែលលោកនិយម ហៅថា ទេពតាមាន ។ល។

៤- បរមាយ សិរិយុតិយ ជោតន្តីតិ ទេវា ។ល។ អ្នកដែលរុងរឿងដោយរស្មីនៃសិរី យ៉ាងឧត្តមទេពតាមាន ។ល។

៥- គុណវុត្តិកេហិ ថោមិយន្តីតិ ទេវា ។ល។ អ្នកដែលមានគេសរសើរដោយការកើត ហៅថា ទេពតាមាន ។ល។

៦- ទស្សនំ សោតុំ សោភាវិសេសយោគេន គមិយន្តីតិ ទេវា ។ល។ អ្នកដែលមានគេចង់ឃើញចង់ស្តាប់ ដោយលំអជាពិសេស ហៅថាទេពតាមាន ។ល។

៧- យថិច្ឆិតដ្ឋានប្បវេសយាតគមនេន គច្ឆន្តីតិ ទេវា ។ល។ អ្នកទៅបានក្នុងទីផ្សេងៗ មិនមានទើសទាល់ ហៅថា ទេពតា មាន ។ល។

៨- អានុភាវសម្បត្តិយា តំ តំ កិច្ចំ និបាទេតុំ សក្កោន្តីតិ ទេវា បាតុម្ហាហារជិកាទយោ អ្នកអាចធ្វើកិច្ចនោះៗ ឲ្យសម្រេច

បានតាមសេចក្តីបំណង ដោយអានុភាព ហៅថា ទេវតា មាន ទេវតាជាន់ចាតុម្មហារាជិកា ជាដើម ។

បទវិគ្រោះទាំង ៨ យ៉ាងដែលពោលមកនេះ សំដៅដល់ ឧប្បត្តិទេវតា គឺទេវតាដែលជាឧបបាតិកកើតឡើងឯងក្នុង ឋានសួគ៌ ហៅថាទេវតាដោយជាតិ ចំណែកទេវតាដោយធម៌ គឺដោយសេចក្តីបរិសុទ្ធិល្អ បានដល់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងព្រះអរហន្តទាំងឡាយនោះ លោកចងជាបទវិគ្រោះ បំភ្លឺ សេចក្តីថាៈ

១– ទិព្វន្តិ កីឡន្តិ បរមាយ ឈានកីឡាយាតិ ទេវា វិសុទ្ធិ ទេវា លោកដែលលេងដោយការលេងឈានយ៉ាងក្រៃលែង ហៅថា ទេវតា បានដល់វិសុទ្ធិទេវតា ។

២– វិជេតុំ ឥច្ឆន្តិ បដិបក្ខន្តិ ទេវា ។ល។ អ្នកដែលត្រូវការ ឈ្នះនូវរបស់ដែលជាសត្រូវ គឺកិលេសហៅថា ទេវតា បាន ដល់វិសុទ្ធិទេវតា។

៣ បរមសុខុមញ្ញាណ វិសេសវិសយំ អត្ថំ វោហរន្តីតិ ទេវា



www.budinst.gov.kh www.elibraryofcambodia.org

។ល។ លោកដែលពោលពាក្យសុទ្ធតែជាវិស័យយ៉ាងវិសេសនៃញាណដ៏សុខុមក្រៃលែង ហៅថាទេពតា បានដល់វិសុទ្ធិទេពតា ។

៤ ជោតន្តិ សព្វកិលេស ទោសកលហា បរមវិសុទ្ធាយ ឈានផុតិយាតិ ទេវា ។ល។ លោកដែលរុងរឿងដោយសេចក្ដីរុងរឿងនៃឈានដ៏បរិសុទ្ធល្អិតក្រៃលែង ហៅថាទេពតា បានដល់វិសុទ្ធិទេពតា ។

៥- ថោមិយន្តិ វិញ្ញាតសភាវេហិ បរមនិម្មលគុណវិសេសយោគតោតិ ទេវា ។ល។ លោកដែលគេសរសើរ ដោយសភាវៈធម៌ដែលលោកដឹងហើយ ដោយលោកមានគុណវិសេសដ៏រកមន្ទិលគ្មាន ហៅថា ទេពតា បានដល់វិសុទ្ធិទេពតា។

៦- កាមិយន្តិ អនុត្តរបុញ្ញក្ខេត្តតាយ ទដ្ឋុំ សោតុំ បូជិតុញ្ចាតិ ទេវា ។ល។ លោកដែលគេចង់ឃើញ ចង់ស្ដាប់ ចង់បូជា ដោយហេតុដែលលោកជាស្រែបុណ្យយ៉ាងខ្ពង់ខ្ពស់ ហៅថា ទេពតា បានដល់វិសុទ្ធិទេពតា ។

www.budinst.gov.kh www.elibraryofcambodia.org

៧. គច្ឆន្តិ អមតមហានិព្វានំ អបញ្ញាតមនីយាយ គតិ យាតិ ទេវា ។ ល ។ លោកដែលទៅកាន់អមតមហានិព្វាន ដោយអាការមិនត្រឡប់ ហៅថា ទេវតា បានដល់វិសុទ្ធិទេវតា

៨ - សណ្ដេន្តិ ចិត្តានំ ញត្វា សត្តេ ហិតេ និយោ ជេត្វា អមតមហានិព្វានសុខេ បតិដ្ឋាបេន្តិ ទេវា វិសុទ្ធិ ទេវា។លោកដែលអាចដឹងវារៈចិត្តរបស់បុគ្គលទាំងឡាយ ហើយ ដឹកនាំឲ្យតាំងនៅ ក្នុងរបស់ដែលជាគុណប្រយោជន៍ នឹងឲ្យ តាំងនៅក្នុងអមតមហានិព្វានសុខ ហៅថា ទេវតា បានដល់ វិសុទ្ធិទេវតា ។

ទេវតា ៣ ប្រភេទ

កាលសង្កេតមើលតាមដែលពោលមកនេះ នឹងឃើញ បានថា ទេវតា មាន ៣ ប្រភេទគឺ

១ - សម្មតិទេវតា បានដល់បំពួកក្សត្រិយ៍ មានព្រះ រាជា ព្រះអគ្គមហេសី ព្រះរាជកុមារកុមារី ជាដើម ។

២ - ឧបត្តិទេវតា បានដល់ទេវតាដែលនៅក្នុងឋាន

www.budinst.gov.kh www.elibraryofcambodia.org

សួគ៌ទាំង ២៦ ជាន់ មានចាតុម្មហារាជិកាជាដើម ។

៣ - វិសុទ្ធិទេវតា បានដល់ព្រះខីណាស្រព គឺ ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្ត ។

## ទីនៅរបស់ទេវតាទាំង ៣ ប្រភេទ

ទេវតាប្រភេទទី ១ នៅក្នុងមនុស្សលោកតែម្យ៉ាង ; ប្រភេទទី ២ : នៅក្នុងមនុស្សលោកខ្លះ នៅក្នុងទេវលោក និងព្រហ្មលោកខ្លះ ដែលនៅក្នុងមនុស្សលោក ហៅថា រុក្ខទេវតាខ្លះ ភុម្មទេវតាខ្លះ ដែលនៅក្នុងឋានសួគ៌នោះ ហៅថា កាមាវចរទេវតាខ្លះ រូបាវចរទេវតាខ្លះ អរូបាវចរទេវតាខ្លះ; ប្រភេទទី ៣ នៅក្នុងមនុស្សលោកប៉ុណ្ណោះ រួមសេចក្តីប្រភេទទី ១-៣ មិនបាច់អធិប្បាយដល់ទីនៅដោយពិស្តារ ព្រោះជាទីចូលចិត្តងាយ បំណែកប្រភេទទី ២ សូមសំដែងទុកដោយពិស្តារ ព្រោះជាការដឹងបានដោយក្រ ។

បាក់នឹងសួរថា កាលសំដែងទុកដោយពិស្តារហើយ នឹងដឹងបានងាយឬ? សូមតបថាដឹង តែមិនឃើញ ។

www.budinst.gov.kh www.elibraryofcambodia.org

បើនឹងថា ឲ្យដូចភ្នែកឃើញ តើបានឬមិនបាន? ព្រោះអ្វី? មិនបានព្រោះជាធម្មតារបស់ដែលមើលមិនឃើញ នឹងនិយាយឲ្យដូចភ្នែកឃើញមិនបាន ។នេះអ្នកប្រាជ្ញទាំងឡាយដែលកើតមកមុនយើង បានគិតមកយូរយាណាស់ហើយ មានសរសេរគូជារូបភាពជាសញ្ញាទុកឲ្យយើងមើលតាមឋានទីផ្សេង ៗ [(១)] ។

ឋានសួគ៌ ២៦ ជាន់

ក្នុងសាលេយ្យកសូត្រ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងអំពីឋានសួគ៌ ២៦ ជាន់ គឺៈ ចាតុម្មហារាជិកា, តាវត្តឹង្ស, យាមា, តុសិត, និម្មានរតី, បរនិម្មិតវសវត្តី, ព្រហ្មបារិសជ្ជា, ព្រហ្មបុរោហិតា, មហាព្រហ្មា, បរិត្តាភា, អប្បមាណាភា, អាភស្សរា, បរិត្តសុភា, អប្បមាណសុភា, សុភកិណ្ហា, វេហប្ផលា, អវិហា អតប្បា, សុទស្សា, សុទស្សី, អកនិដ្ឋា, អាកាសានញ្ចាយតន,

---

១ កាលពុទ្ធសម័យថាៈ ព្រះអង្គទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ថាអ្នកទាំងឡាយដែលបានឃើញទេវតាដែរឬទេ? ចូរមើលពួកស្ដេចលិច្ឆវីនោះចុះដូចហើយ! (ព្រះវិភត្តញាណ កៅ-ស៊ឹម) ។

វិញ្ញាណញ្ចាយតន, អកិញ្ចញ្ញាយតន, នេវសញ្ញានាសញ្ញាយតន, (រាប់អសញ្ញីភពបូលផងជា ២៦) ។

ឋានសួគ៌ទាំង ២៦ ជាន់នេះ មានពាក្យប្រែកែពន្យល់ តាមបទវិគ្គហ ដែលមានមកក្នុងទីផ្សេង ៗ ដូចតទៅនេះ គឺ:

១– ជាន់ចាតុម្មហារាជិកា លោកពោលថា “ចតុន្នំ មហារាជានំ និវាសនដ្ឋានភូតេ ចតុមហារាជេ ភវាតិ ចាតុម្មហារាជិកា ភពក្នុងមហារាជទាំង ៤ ដែលជាទីនៅរបស់មហារាជ ៤ ឈ្មោះថាជាន់ចាតុមហារាជិកា [1] ។

“ធតរដ្ឋវិរុឡ្ហកវិរូបក្ខកុវេរសង្ខាតា ចត្តារោ មហារាជានោ ឯត្ថ វសន្តីតិ ចាតុម្មហាជិកា” មហារាជ ៤ គឺ ធតរដ្ឋ ១ វិរុឡ្ហកៈ ១ វិរូបក្ខៈ ១ កុវេរៈ ១ នៅក្នុងភពនោះ ៗ ឈ្មោះថា ចាតុម្មហារាជិកា[2] ។

២– ជាន់តាវត្តិង្ស “តេត្តិំស សហបុញ្ញការិនោ ឯត្ថ និព្វត្តាតិ តំ សហចរិតំ ឋានំ តេត្តិំសំ ។ តទេវ តាវត្តិំសំ ។ តំ និវាសោ ឯតេសន្តិ តាវតឹសា” ទីដែលហៅថា តាវតិង្ស

១– ដីកាអភិធម្មត្ថសង្គហ ។ ២– ដីកាសមចិត្តសូត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះជាទីកើតទីនៅរបស់មនុស្សទាំង ៣៣ នាក់ដែលធ្វើបុណ្យ រួមគ្នា [១] ។ តេត្តឹសជនា តត្ថ ឧបន្នាតិ តាវតឹសា ។ អបិច តាវតឹសាតិ តេសំ ទេវានំ នាមមេវ" ដែលហៅថា តាវតិង្ស ព្រោះមនុស្សទាំង ៣៣ នាក់នោះ កើតក្នុងទីនោះ ។ ម្យ៉ាងទៀត ពាក្យថាតាវត្តិង្ស ជាឈ្មោះរបស់ទេវតាពួកនោះ ឯង [២] ។

៣– ជាន់យាមា "ទិព្វសុខំ យាតា បយាតា សម្បត្តាតិ យាមា" ដែលហៅថាជាន់យាមា ព្រោះទេវតាជាន់នេះ ជាអ្នក នៅដល់ព្រម គឺដល់នូវទិព្វសុខ ។

៤– ជាន់តុសិត "តុដ្ឋា បហដ្ឋាតិ តុសិតា" ដែល ហៅថា ជាន់តុសិត ព្រោះជាអ្នកត្រេកអរីករាយ ។

៥– ជាន់និម្មានរតី "បកតិ បដិយត្តារម្មណតោ អតិរេ-កេន រមិតុកាមតាលេ យថា រុចិយេ កាមភោគេ និម្មិ-

---

១– ដីកាសមចិត្តសូត្រ ។ ២– អាចរិយភិទ ។

និត្វា រមន្តិ និម្មានរតី „ ទីដែលហៅថាជាន់និម្មានរតី ព្រោះទេពតាពួកនេះនិម្មិតកាមភោគ បានតាមបំណង ក្នុងវេលាមានសេចក្ដីត្រូវការ នឹងសេចក្ដីត្រេកអររីករាយកើតឡើង កើតលើសអារម្មណ៍ដែលបុណ្យតាក់តែងតាមប្រក្រតី ។

៦_ ជាន់បរនិម្មិតវសវត្តី „ ចិត្តាចារំ ញត្វា បរេហិ និម្មិតេសុ ភោគេសុ វសំ វត្តេន្តិ បរនិម្មិតវសវត្តី" ដែលហៅថាបរនិម្មិតវសវត្តី ព្រោះទេពតាជាន់នេះ មានអំណាចក្នុងភោគ ដែលទេពតាពួកដទៃដឹងអធ្យាស្រ័យចិត្តហើយនិម្មិតឲ្យ ។

៧_ ជាន់ព្រហ្មបរិសជ្ជា ‘ មហាព្រហ្មានំ បារិសជ្ជា បារិចារិកាតិ ព្រហ្មបារិសជ្ជា „ ដែលហៅថា ព្រហ្មបារិសជ្ជា ព្រោះព្រហ្មជាន់នេះ ជាបរិស័ទគឺជាអ្នកបំរើរបស់មហាព្រហ្ម ។

៨_ ជាន់ព្រហ្មបុរោហិតា " តេសំ បុរោហិតភាវេ ឋិតាតិ ព្រហ្មបុរោហិតា „ ដែលហៅថា ព្រហ្មបុរោហិតា ព្រោះព្រហ្មជាន់នេះ តាំងនៅក្នុងភាពជាបុរោហិតរបស់ព្រះព្រហ្ម។

៩_ ជាន់មហាព្រហ្ម "វណ្ណវន្តតាយ ចេវ ទីឃាយុក-

www.budinst.gov.kh www.elibraryofcambodia.org

តាយ ប មហន្តោ ព្រហ្មាតិ មហាព្រហ្មា„ ដែលហៅថា មហាព្រហ្ម ព្រោះព្រហ្មនេះ ជាអ្នកធំដោយវណ្ណនឹងអាយុយឺនយូរ

១០ ជាន់បរិត្តាភា “បរិត្តា អាភា ឯតេសន្តិ បរិត្តាភា” ដែលហៅថា បរិត្តាភា ព្រោះព្រហ្មជាន់នេះ មានពន្លឺរស្មីតិច ។

១១- ជាន់អប្បមាណាភា “អប្បមាណាភា អាភា ឯតេសន្តិ អប្បមាណាភា” ដែលហៅថា អប្បមាណាភា ព្រោះព្រហ្មជាន់នេះមានពន្លឺរស្មីរកប្រមាណមិនបាន ។

១២ ជាន់អាភស្សរា “ទណ្ឌទីបិកាយ អច្ចិរិយ ឯតេសំ សរីរតោ អាភា ឆិជ្ជិត្វា បច្ចិជ្ជិត្វា បតន្តីវិយ សរតិ វិសរតីតិ អាភស្សរា” ដែលហៅថា អាភស្សរា ព្រោះជាន់នេះ មានរស្មីចេញអំពីកាយ ដូចអណ្តាតភ្លើងឬពន្លឺប្រទីប ។

១៣ - ជាន់បរិត្តសុភា “បរិត្តា សុភា ឯតេសន្តិ បរិត្តសុភា” ដែលហៅថា បរិត្តសុភា ព្រោះព្រហ្មជាន់នេះ មានសេចក្តីល្អតិច ។

១៤- ជាន់អប្បមាណសុភា “អប្បមាណាសុភា ឯតេសន្តិ

www.budinst.gov.kh www.elibraryofcambodia.org

អប្បមាណសុភា" ដែលហៅថា អប្បមាណសុភា ព្រោះព្រហ្ម ជាន់នេះ មានសេចក្ដីល្អរកប្រមាណមិនបាន ។

១៥ ជាន់សុភកិណ្ហា "សុភេន ឱភាសេន កិណ្ណា វិកិណ្ណា សុភេន សរីរប្បភាវណ្ណេន ឯកគ្ឃនា សុវណ្ណមញ្ជូសាយ ឋបិតសមុជ្ជលិតកាញ្ចនបិណ្ឌសស្សិរីកាតិ សុភកិណ្ហា" ដែលហៅថា សុភកិណ្ហា ព្រោះព្រហ្មជាន់នេះ ច្រើនទៅដោយសេចក្ដីល្អ គឺល្អដោយរស្មី ដែលផ្សាយចេញចាករាងកាយ មានរស្មីប្រៀបដូចផែនមាសក្នុងហិបមាស ។

១៦_ ជាន់វេហប្ផលា "វិបុលាផលា ឯតេសន្តិ វេហប្ផលា" ដែលហៅថា វេហប្ផលា ព្រោះព្រហ្មជាន់នេះ មានផលវិបុលវិសេសវិសាល ។

១៧_ ជាន់អវិហា "អត្តនោ សម្បត្តិយា ន វិហាយន្តិ ន វិហាយន្តីតិ អវិហា" ដែលហៅថា អវិហា ព្រោះព្រហ្មជាន់នេះ មិនសាបសូន្យចាកសម្បត្តិរបស់ខ្លួន ។

១៨_ ជាន់អតប្បា "ន កិញ្ចិ សត្តំ តាបេន្តីតិ

អតប្បា" ដែលហៅថា អតប្បា ព្រោះព្រហ្មជាន់នេះ មិនធ្វើឲ្យនរណាមួយក្តៅក្រហាយ ។

១៩ ជាន់សុទស្សា "សុន្ទរា ទស្សនា អភិរូបា បាសាទិកាតិ សុទស្សា" ដែលហៅថា សុទស្សា ព្រោះព្រហ្មជាន់នេះ មានរូបល្អផើតគួរទស្សនា ។

២០ ជាន់សុទស្សី "សុដ្ឋុ បស្សន្តិ សុន្ទរបេតេសំ វា ទស្សនន្តិ សុទស្សី" ដែលហៅថា សុទស្សី ព្រោះព្រហ្មជាន់នេះ មានសេចក្តីយល់ឃើញដ៏ល្អប្រពៃ ។

២១ ជាន់អកនិដ្ឋា "នត្ថេត្ថ កនិដ្ឋាតិ អកនិដ្ឋា" ដែលហៅថា អកនិដ្ឋា ព្រោះព្រហ្មជាន់នេះ មិនមានអ្នកតូច ៗ មានសុទ្ធតែអ្នកធំ ដោយគុណសម្បត្តិនឹងភពសម្បត្តិគ្រប់យ៉ាង ។[១]

២២- ជានអាកាសានញ្ចាយតនៈ "អាកាសានញ្ចមេវ អាយតនំ អាកាសានញ្ចាយតនំ" ដែលហៅថា អាកាសាន

---

១- តាំងអំពីជាន់យាមាដល់អកនិដ្ឋានេះ មានទូរក្នុងអដ្ឋកថាពៃកង្គ

ញ្ញាយតនៈ បានដល់អាយតនៈ គឺអាកាសដែលមិនមានទីបំផុត ។

អធិប្បាយថា: ព្រហ្មជាន់នេះកាលជាមនុស្ស បានបំរើនអរូបជ្ឈាន កាន់ថាអាកាស មិនមានទីបំផុត សំឡឹងមើលអាកាស ដោយអំណាចការពង្រីកកសិណ ឃើញថាអាកាសមិនមានទីបំផុត កាលស្លាប់អំពីមនុស្ស ទើបបានទៅកើតជាព្រហ្មជាន់នេះ ។

២៣- ជាន់វិញ្ញាណញ្ចាយតនៈ វិញ្ញាណញ្ចំ អាយតនំ វិញ្ញាណញ្ចាយតនំ ទីដែលហៅថា វិញ្ញាណញ្ចាយតនៈនេះ បានដល់អាយតនៈ គឺវិញ្ញាណមិនមានទីបំផុត ។

អធិប្បាយថា: ព្រហ្មជាន់នេះ កាលជាមនុស្ស បានបំរើនអរូបជ្ឈាន សំឡឹងមើលចិត្តរបស់ខ្លួន ឃើញថាមិនមានទីបំផុត ទើបប្រកាន់ថាចិត្ត ឬវិញ្ញាណនេះ មិនមានទីបំផុតកាលស្លាប់អំពីមនុស្ស ទើបបានទៅកើតជាព្រហ្មជាន់នេះ ។

២៤- ជាន់អកិញ្ចញ្ញាយតនៈ "អាកិញ្ចញ្ញំ អាយតនំ

www.budinst.gov.kh www.elibraryofcambodia.org

អកិញ្ចញ្ញាយតនំ" ដែលហៅថាអកិញ្ចញ្ញាយតនៈនេះ បានដល់អាយតនៈគឺសេចក្ដីមិនមានអ្វី ៗ

អធិប្បាយថា: ព្រហ្មជាន់នេះ កាលជាមនុស្ស បានចំរើនអរូបជ្ឈាន សំឡឹងមើលអាកាសនឹងវិញ្ញាណ ឃើញថាមិនមានអ្វីជាតួខ្លួន ទើបប្រកាន់ថាមិនមានអ្វីជាអារម្មណ៍ កាលស្លាប់អំពីមនុស្ស ទើបបានទៅកើតជាព្រហ្មជាន់នេះ ។ នេះជាន័យទី ១ ។

ន័យទី ២ លោកអធិប្បាយថា "អាកិញ្ច" ទុកថា "នាស្ស កិញ្ចនត្ថិ អកិញ្ចនំ" មិនមានគ្រឿងកង្វល់ដោយទីបំផុតអំពីចិត្ត ដែលនឹងពើតរលត់ក៏មិនមាន ដូចនេះខ្លះ "កិញ្ចនំ អប្បមត្តកំ អន្តមសោ ភង្គមត្តម្បិ" គ្រឿងកង្វល់សូម្បីបន្តិចបន្តួច ដោយទីបំផុតអំពីចិត្តក៏មិនមានដូចនេះខ្លះ ។

ន័យទី ៣ ថា "កិញ្ចនត្ថិ កិញ្ចិបិ" ពាក្យថា "កិញ្ចនំ" ប្រែថា "អ្វី ៗ" ន័យនេះត្រូវគ្នានឹងន័យទី ១ គឺជាន់នេះ ប្រកាន់សេចក្ដីមិនមានអ្វីជាអារម្មណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

២៥– នេវសញ្ញានាសញ្ញាយតនៈ "នេវសញ្ញានាសញ្ញមេវ អាយតនំ នេវសញ្ញានាសញ្ញាយតនំ" ដែលហៅថា នេវសញ្ញានាសញ្ញាយតនៈនេះ បានដល់អាយតនៈ គឺមិនមានសញ្ញានឹងថាមិនមានសញ្ញាក៏មិនមែន (១) ។

អធិប្បាយថា ព្រហ្មជាន់នេះ កាលជាមនុស្សបានចំរើនអរូបជ្ឈាន ធ្វើវិធីចិត្តឲ្យល្អិតទីបំផុត រហូតពោលបានថា មិនមានសញ្ញា គឺការចាំអ្វីមិនបានសោះឡើយ ប្រហែលនឹងមនុស្សដេកលក់យ៉ាងស៊ប់ អស់សញ្ញាយ៉ាងគ្រោតគ្រាត តែថាគ្មានសញ្ញាសោះក៏មិនមែនព្រោះនៅមានសញ្ញាដែលល្អិតសុខុម ។

២៦– ជាន់អសញ្ញី "សញ្ញាវិរហិតា សត្តាតិ អសញ្ញី" ទីដែលហៅថា អសញ្ញីព្រោះព្រហ្មជាន់នេះ មិនមានសញ្ញាសោះឡើយ ។

អធិប្បាយថា ព្រហ្មជាន់នេះ កាលជាមនុស្ស បានបួស

---

១ ភពដែលមានសញ្ញាដូចជាឥតសញ្ញា ហៅថា នេវសញ្ញានាសញ្ញាភព (ព្រះវិភង្គញ្ញាណ (៣ – ស៊ុម) ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសាសនាណាមួយពិចារណាឃើញទោសក្នុងចិត្ត គឺឃើញថា រាគៈ ទោសៈ មោហៈ ជាដើម សុទ្ធតែកើតមកអំពីចិត្ត ទើបតាំងចិត្តកំណត់ចិត្ត ដោយវិធីទឹកង់នៅជានិច្ច ពិចារណាជាប់នៅជានិច្ចថា "ចិត្តមិនមាន" ដរាបនៅនឹងតែមួយ ដែលហៅថា ឈានឈាន ត្រាតែស្លាប់អំពីមនុស្ស ទើបបានទៅកើតជាព្រហ្មជាន់នេះ មានតែរូប មិនមានវេទនា សញ្ញា សង្ខារ វិញ្ញាណអ្វី នឹងវេលាស្លាប់អំពីមនុស្សនោះ បើស្លាប់ក្នុងឥរិយាបថណា កាលកើតជាព្រហ្មក៏កើតក្នុងឥរិយាបថនោះ តាំងនៅក្នុងឥរិយាបថនោះរហូតដល់ចុតិ វេលានឹងចុតិនោះមានសញ្ញា គឺចិត្តកើតឡើងមុន ទើបចុតិ ។

ឋានសួគ៌ ៣ ប្រភេទ

ឋានសួគ៌ទាំង ២៦ ជាន់ តាមដែលពោលមកហើយនេះ បែងចែកជា ៣ ប្រភេទគឺ ៦ ជាន់ខាងដើម ជាកាមាវចរ ជាទេវលោក បំណែក ២០ ជាន់ខាងចុងជាព្រហ្មលោក នឹងព្រហ្មលោក ២០ ជាន់នោះ បែងជា ២ ផ្នែកគឺ ១៦ ជាន់ខាងដើមជា

www.budinst.gov.kh www.elibraryofcambodia.org

រូបព្រហ្ម ៤ ជាន់ខាងចុងជា អរូបព្រហ្ម ។ ចំពួករូបព្រហ្ម ១៦ ជាន់នោះ កើតដោយរូបជ្ឈាន ៤ ចាត់ដូចនេះគឺៈ ៣ ជាន់ខាងដើមបានដល់ព្រហ្មបារិសជ្ជា ១, ព្រហ្មបុរោហិតា ១, មហាព្រហ្មា ១, ជាជាន់បឋមជ្ឈាន ។ ជាន់បរិត្តាភា ១, អប្បមាណាភា ១ អាភស្សរា ១ ជាជាន់ទុតិយជ្ឈាន ។ ជាន់បរិត្តសុភា ១, អប្បមាណសុភា ១, សុភកិណ្ហា ១ ជាជាន់តតិយជ្ឈាន ។ ៧ ជាន់ទៀត គឺអសញ្ញី ១, វេហប្ផលា ១, អវិហា ១, អតប្បា ១ សុទស្សា ១, សុទស្សី ១, អកនិដ្ឋា ១, ជាជាន់ចតុត្ថជ្ឈាន ។ ៤ ជាន់ខាងចុង មានអាកាសានញ្ចាយតនៈជាដើម ជាជាន់អរូបជ្ឈាន ៤ ។ និងព្រហ្មលោក ៩ ជាន់ គឺសុទ្ធាវាស ៥ បានដល់ជាន់អវិហា ១, អតប្បា ១, សុទស្សា ១, សុទស្សី ១, អកនិដ្ឋា ១ និងអរូបព្រហ្ម ៤ មានអាកាសានញ្ចាយតនជាដើម ជាទីកើតរបស់ព្រះអនាគាមិបុគ្គល ។ ចំណែកព្រះអរិយជាន់ព្រះសោតា, សកទាគាមី បើកើតក្នុងជាន់រូបព្រហ្មហើយ មិនត្រឡប់ចុះមកកើតក្នុងមនុស្សលោកនេះទៀតទេ ។

www.budinst.gov.kh www.elibraryofcambodia.org

កាមសេវនកិច្ច ក្នុងឋានសួគ៌ ២៦ ជាន់

ឋានសួគ៌ទាំង ២៦ ជាន់ ដែលពោលមកហើយខាងដើមនេះ បានបែងជា ៣ ប្រភេទ គឺកាមាវចរ ១ រូបាវចរ ១ អរូបាវចរ១ ។ ៦ ជាន់ខាងដើម ដែលជាកាមាវចរនោះ គឺនៅមានចិត្តជាប់ជំពាក់នឹងកាមារម្មណ៍ នៅមានកាមសេវនកិច្ច តែគ្រោតគ្រាតនឹងល្អិតជាងគ្នាជាជាន់ ៗ គឺជាន់ចាតុម្មហារាជិកាតាវតឹង្ស សំរេចកាមសេវនកិច្ច ដោយការរួមប្រវេណី ដូចមនុស្សដែរ ។ ជាន់យាមាសំរេចកាមសេវនកិច្ច ដោយការស្ទាបអង្អែលគ្នា ។ ជាន់តុសិត សំរេចកាមសេវនកិច្ចដោយការចាប់ដៃគ្នា ។ ជាន់និម្មានរតី ត្រឹមតែញញឹមទទួលគ្នាប៉ុណ្ណោះ ។ ជាន់បរនិម្មិតវសវត្តី ត្រឹមតែសំឡឹងមើលគ្នាប៉ុណ្ណោះ តែមិនមានសុក្កសម្ភៈ ។

ដោយហេតុដូចជាមកនេះ លោកទើបពោលថា ព្រះឥន្ទមានកូនដល់ពាន់ មានសុវីជ័យ នឹង សុសិមទេវបុត្រជាដើម



www.budinst.gov.kh www.elibraryofcambodia.org

ដែលសុទ្ធតែកើតអំពីព្រះអគ្គមហេសីរបស់ព្រះឥន្ទនោះឯង ។ ក៏បុរសដែលកើតលើភ្លៅរបស់ទេពតា ហៅថា ទេវបុត្រ ស្ត្រី ហៅថា ទេពធិតា បុត្រនិងធិតារបស់ទេពតា រមែងកើតលើភ្លៅ បើជាស្ត្រីដែលកើតក្នុងទីដេក ចាត់ជានាងបំរើ បើកើតក្បែរខាងទីដេក ចាត់ជាភ្នាក់ងារគ្រឿងសំអាង បើកើតក្នុងកណ្តាលវិមានចាត់ជាអ្នកបំរើ ។

## ព្រះរាជាក្នុងឋានសួគ៌ ៦ ជាន់

ក្នុងឋានសួគ៌ទាំង ៦ ជាន់ មានចាតុម្មហារាជិកាជាដើមនោះ មានព្រះរាជាគ្រប់ជាន់ គឺជាន់ ចាតុមៈ តាវតឹង្ស ព្រះឥន្ទជាព្រះរាជា ។ ជាន់យាមា សុយាមទេព ជាព្រះរាជា ។ ជាន់តុសិត សន្តុសិតទេព ជាព្រះរាជា ។ ជាន់និម្មានរតី និម្មិតទេព ជាព្រះរាជា ។ ជាន់បរនិម្មិតវសវតី វសវតីទេព ជាព្រះរាជា ។ ក្នុងជាន់ បរនិម្មិតវសវតី មានព្រះរាជា ១ អង្គទៀត គឺព្រះបាទមារជា ធំនៅក្នុងចំណែកមួយរបស់ឋានសួគ៌ជាន់នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

បំណែកឋានសួគ៌ ២០ ជាន់នោះ មិនមានកាមសេវនកិច្ច ឡើយ ព្រោះមិនមានភេទស្ត្រី និងបុរសក្នុងព្រហ្មលោក ។ និងដែលពោលថា ព្រហ្មលោកទាំងនោះ ចាត់តាមឈាននោះ គឺអ្នកចំរើនបឋមជ្ឈានបានតិច កើតក្នុងព្រហ្មបារិសជ្ជា បើបានល្មមយ៉ាងកណ្តាល កើតក្នុងព្រហ្មជាន់ព្រហ្មបុរោហិតា បើបានយ៉ាងប្រណីត កើតក្នុងជាន់មហាព្រហ្ម ។ អ្នកចំរើនទុតិយជ្ឈានបានតិច កើតក្នុងជាន់បរិត្តាភា បើបានយ៉ាងកណ្តាល កើតក្នុងជាន់អប្បមាណាភា បើបានយ៉ាងប្រណីត កើតក្នុងជាន់អាភស្សរា ។ អ្នកចំរើនតតិយជ្ឈានបានតិច កើតក្នុងជាន់បរិត្តសុភា បានយ៉ាងកណ្តាល កើតក្នុងជាន់អប្បមាណសុភា បានយ៉ាងប្រណីត កើតក្នុងជាន់សុភកិណ្ហា ។ អ្នកចំរើនចតុត្ថជ្ឈានកើតក្នុងព្រហ្មលោក ១១ ជាន់ មានអសញ្ញីជាដើម ។ បំណែកអរូបព្រហ្ម ៤ ជាន់ទៀត ជាទីកើតរបស់អ្នកបានអរូបជ្ឈាននឹងព្រះអនាគាមី ។

www.budinst.gov.kh www.elibraryofcambodia.org

ធៀបអាយុមនុស្សនឹង អាយុសួគ៌

៥០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ ជាន់ចាតុមៈ ៥០០ ឆ្នាំទិព្វ ជាអាយុរបស់សួគ៌ជាន់ចាតុមៈ៥០០ឆ្នាំទិព្វនោះ ត្រូវជា ៩ លានឆ្នាំ ក្នុងមនុស្ស ។

១០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់តាវតិង្ស ១០០០ ឆ្នាំទិព្វ ជាអាយុរបស់ឋានសួគ៌ជាន់តាវតិង្ស គិតជាឆ្នាំក្នុងមនុស្សបាន ៣ កោដិ ៦ លានឆ្នាំ ។

២០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់របស់ឋានសួគ៌ជាន់យាមា ២០០០ ឆ្នាំទិព្វ ជាអាយុរបស់ឋានសួគ៌ជាន់យាមា គិតជាឆ្នាំមនុស្សបាន ១៤ កោដិ ៤ លានឆ្នាំ ។

៤០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌តុសិត ឋានសួគ៌ជាន់តុសិត មានអាយុ ៤០០០ ឆ្នាំទិព្វ គិតជាឆ្នាំមនុស្សបាន ៥៧ កោដិ ៦ លានឆ្នាំ ។

៨០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់និម្មានរតី ឋានសួគ៌ជាន់និម្មានរតី មានអាយុ ៧០០០ ឆ្នាំទិព្វ

www.budinst.gov.kh www.elibraryofcambodia.org

គិតជាឆ្នាំក្នុងមនុស្ស បាន ២៣០ កោដិ ៤ លានឆ្នាំ ។

១៦០០ ឆ្នាំមនុស្ស ជា ១ ថ្ងៃ ១ យប់ របស់ឋានសួគ៌ជាន់បរនិម្មិតវសវត្តី ឋានសួគ៌ជាន់បរនិម្មិតវសវត្តិមានអាយុ ១៦០០ ឆ្នាំទិព្វ គិតជាឆ្នាំក្នុងមនុស្សបាន ៩២១ កោដិ ៦ លានឆ្នាំ ។

ដែលថាមកនេះ ជាអាយុឋានសួគ៌ជាន់កាមាវចរ ៦ ដែលហៅថា ទេវលោក បំណែកព្រហ្មលោកមានអាយុច្រើនណាស់ ដូចនឹងពោលទុកក្នុងទីនេះគឺ៖ ។

ជាន់ព្រហ្មបារិសជ្ជា សេសមួយក្នុងចំណែកបី ១/៣ របស់កប្បជាកំណត់អាយុ ។

ជាន់ព្រហ្មបុរោហិត កន្លះកប្ប ។ ជាន់មហាព្រហ្ម ១ កប្ប ។ ជាន់បរិត្តាភា ២ កប្ប ។ តពីនេះទៅច្រើនជាងគ្នា ១ ប៉ុន ៗ គ្នា ជាទ្វេគុណ ។

ធៀបអាយុសួគ៌ នឹងអាយុនរក

អាយុក្នុងឋានសួគ៌ជាន់ចាតុម: ៥០០ ឆ្នាំទិព្វ ជា ១ ថ្ងៃ ១ យប់ ក្នុងសញ្ជីវនរក ៗ នោះ មានកំណត់អាយុ ៥០០ ឆ្នាំ ។

www.budinst.gov.kh www.elibraryofcambodia.org

អាយុ ១០០០ ឆ្នាំទិព្វ ក្នុងតាវតឹង្សជា ១ ថ្ងៃ ១ យប់ក្នុងកាឡសុត្តនរក ៗ នោះមានកំណត់អាយុ ១០០០ ឆ្នាំ ។

កំណត់អាយុក្នុងជាន់យាមា ២០០០ ឆ្នាំទិព្វ ជាថ្ងៃ ១ យប់ក្នុងសង្ឃាតនរក.ៗនោះ មានកំណត់អាយុ ២០០០ ឆ្នាំ ។

កំណត់អាយុ ៤០០០ ឆ្នាំទិព្វក្នុងជាន់តុសិត ជា ១ ថ្ងៃ ១ យប់ ក្នុងរោរុវនរក ៗ នោះ មានកំណត់អាយុ ៤០០០ ឆ្នាំ ។

កំណត់អាយុ.ក្នុងជាន់និម្មានរតី ៨០០០ ឆ្នាំទិព្វ ជា ១ ថ្ងៃ ១ យប់ ក្នុងមហារោរុវនរក ៗ នោះ មានកំណត់ ៨០០០ ឆ្នាំ ។

កំណត់អាយុ.ក្នុងជាន់បរនិម្មិតវសវត្តី ១៦ ពាន់ឆ្នាំទិព្វជា ១ ថ្ងៃ ១ យប់ ក្នុងតាបននរក ៗ នោះ មានកំណត់អាយុ ១៦ ពាន់ឆ្នាំ ក្នុងមហាតាបននរក មានកំណត់អាយុកន្លះអន្តរកប្ប ។ ក្នុងអវិចីនរក មានកំណត់អាយុ ១ អន្តរកប្ប ។[1]

វយៈផ្សិហិនស្លូគិ

វយៈផ្សិហិនស្លូគិនោះ លោកពោលទុកក្នុងគម្ពីរលោកនីតិ

១ – អនុដីកានៃវិភង្គ ។

បកសារថា " អសុរបុរតោ ហិ យាវ មនុស្សភូមិតោ ចតុរាសីតិយោជនសហស្សានិ ហោន្តិ" តាំងអំពីអសុរបុរី ហូតដល់បុរីរបស់មនុស្សត្រូវជា ៨៤០០០យោជន៍ ។

"មនុស្សភូមិតោ យាវ មហារាជិកា ទ្វេ ចត្តាឡីសយោជនសហស្សានិ" អំពីមនុស្សរហូតដល់ចាតុមត្រូវជា ៤២០០០ យោជន៍ ។

"តថា ចាតុម្មហារាជិកតោ យាវ តាវតឹសា" អំពីចាតុមរហូតដល់តាវតឹង្សត្រូវជា៤២០០០យោជ៍ ដូចគ្នា ។

"ឥតិ អសុរបុរតោ យាវ តាវតឹសបុរា យោជនានំ ឯកលក្ខំ ឆ ឆហុតំ អដ្ឋសហស្សញ្ច" តាំងអំពីបុរីអសុររហូតដល់តាវតឹង្ស ទើបជារយៈផ្លូវ ១៦៨០០០ យោជន៍ ដូចបានរៀបរាប់មកនោះហើយ ។

"បឋវីតលតោ យាវ តាវតឹសា បន ចតុរាសីតិយោជនសហស្សានិ" បើគិតតាំងអំពីផែនដីឡើងទៅដល់តាវតឹង្សត្រូវជា ៨៤០០០ យោជន៍ ។

www.budinst.gov.kh www.elibraryofcambodia.org

“តាវតឹងសតោ យាវយាមា យោជនានំ បតុលក្ខំ តិន ហុតំ បតុសហស្សំ បតុសតញ្ច” អំពីតាវតឹង្សដល់ទៅយាមា ត្រូវជា ៤៣៤៤០០ យោជន៍ ។

“តាវ យាមតោ យាវ តុសិតា សត្តលក្ខំ បតុរាសីតិ សហស្សំ អដ្ឋសតញ្ច” អំពីយាមាដល់ទៅតុសិតត្រូវជា ពិ៨៤៨០០ យោជន៍ ។

“តុសិតតោ យាវ និម្មានរតិតោ ឯកាទសលក្ខានិ តិន ហុតំ បញ្ចសហស្សំ ទ្វិសតញ្ច” អំពីតុសិតដល់ទៅនិម្មានរតី ត្រូវជា ១១៣៥២០០ យោជន៍ ។

“និម្មានរតិតោ យាវ វសវត្តិតោ ចុទ្ទសលក្ខានិ អដ្ឋន ហុតានិ បញ្ចសហស្សំ ឆ សតញ្ច” អំពីនិម្មានរតី ដល់ទៅ បរនិម្មិតវសវត្តីត្រូវជា ១៤៨៥៦០០ យោជន៍ ។

“វសវត្តិតោ យាវ បឋមជ្ឈានភូមិតោ អដ្ឋារសលក្ខានិ តិនហុតំ ឆ សហស្សញ្ច អំពីបរនិម្មិតវសវត្តី ដល់ជាន់បឋមជ្ឈាន គឺជាន់ព្រហ្មបារិសជ្ជា ត្រូវជា ១៨៣៦០០០យោជន៍ៗ

## ពណ៌នាឋានសួគ៌ជាន់ចាតុម្មហារាជិកា

ពាក្យថា ចាតុម្មហារាជិកា ប្រែថា ពួកទេពតាមាន មហារាជទាំង ៤ ជាប្រធាន គឺៈ ក្នុងឋានសួគ៌ជាន់នេះ មាន មហារាជ ៤ អង្គ គឺ ធតរដ្ឋ ១ វិរុឡ្ហក ១ វិរូបក្ខ ១ វេស្សវណ្ណ១ ឋានសួគ៌ជាន់នេះ តាំងនៅលើកំពូលភ្នំយុគន្ធរ ដែលជាភ្នំទី ២ ក្នុងចំពួកភ្នំ សត្តបរិភណ្ឌ ៗ តពីនេះទៅនឹងនាំសាធករឿង មហារាជ ៤ ៗ

បុរិមញ្ញ ទិសំ រាជា ធតរដ្ឋោ បសាសតិ
គន្ធព្វានំ អធិបតិ មហារាជា យសស្សិនោ

ធតរដ្ឋមហារាជ គ្រប់គ្រងផ្លូវនូវទិសបូព៌ា ជាម្ចាស់នៃពួកគន្ធព្វ។

ទក្ខិណញ្ច ទិសំ រាជា វិរុឡ្ហោ តប្បសាសតិ
កុម្ភណ្ឌានំ អធិបតិ មហារាជា យសស្សិនោ

វិរុឡ្ហកមហារាជ គ្រប់គ្រងផ្លូវនូវទិសទក្សិណ ជាម្ចាស់នៃពួក កុម្ភណ្ឌ ៗ

www.budinst.gov.kh www.elibraryofcambodia.org

បច្ឆិមញ្ច ទិសំ រាជា វិរូបក្ខោ បសាសតិ

នាគានំ អធិបតិ មហារាជា យសស្សិនោ

វិរូបក្ខមហារាជ គ្រប់គ្រងផ្លូវនៅទិសបស្ចិម ជាម្ចាស់នៃពួកនាគ។

ឧត្តរញ្ច ទិសំ រាជា កុវេរោ តប្បសាសតិ

យក្ខានំ អធិបតិ មហារាជា យសស្សិនោ

កុវេរ(១) មហារាជ គ្រប់គ្រងផ្លូវនៅទិសឧត្តរ ជាម្ចាស់នៃពួកយក្ខ

មហារាជទាំង ៤ នេះ សុទ្ធតែមានឫទ្ធិតេជះអំណាចវិស ឆាយសស័ក្តិច្រើននឹងមានឱរសមួយអង្គមួយពាន់ ទ្រង់នាមថា ឥន្ទ ដូចគ្នាទាំងអស់ ។

"បុរិមទិសំ ធតរដ្ឋោ ទក្ខិណេន វិរុឡ្ហកោ

បច្ឆិមេន វិរូបក្ខោ កុវេរោ ឧត្តរំ ទិសំ"

ចូរចាំទុកដោយយ៉ាងនេះថា ទិសបូព៌ា ព្រះបាទធតរដ្ឋ, ទិសទក្សិណ ព្រះបាទវិរុឡ្ហក, ទិសបស្ចិម ព្រះបាទវិរូបក្ខ, ទិសឧត្តរ ព្រះបាទកុវេរៈ ដូចនេះចុះ ! ។

---

១– គឺព្រះបាទវេស្សវ័ណ្ណ ។

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



"សិនេរុស្ស ហិ បាចិនបស្សំ រជតមយំ ទក្ខិណបស្សំ មណិមយំ បច្ឆិមបស្សំ ផលិកមយំ ឧត្តរបស្សំ សោវណ្ណមយំ ។

ផ្លូវទិសបូព៌ានៃភ្នំសិនេរុនោះ សំរេចហើយដោយប្រាក់ ផ្លូវទិសទក្សិណ សំរេចហើយ ដោយកែវមណី ផ្លូវទិសបស្ចិម សំរេចហើយដោយកែវផលិក ផ្លូវទិសឧត្តរ សំរេចហើយ ដោយមាស ។

ផ្លូវទិសឧត្តរ ដែលសំរេចដោយមាសនោះ មានព្រះនគរតាំងនៅ ១០ នគរគឺ អាដានាដា ១ កុសិនាដា ១ បរកុសិនាដា ១ នាដបរិយា ១ បរកុសិតនាដា ១ កបិវន្តៈ ១ ជនោឃៈ ១ នវនវតិយ ១ អម្ពរអម្ពរវតិយ ១ អាឡកមន្ទា ១ ។

មានរាជធានី ១ ទៀត ឈ្មោះវិសាណរាជធានី ជាទីប្រថាប់របស់កុវេរ មហារាជ ដោយហេតុនេះ កុវេរ មហារាជ ទើបទ្រង់ព្រះនាមក្លាយនឹងនាមរាជធានីថា "វេស្សវណ្ណ" ។

ព្រះបាទវេស្សវណ្ណនោះ មានយក្សរក្សកៈ អ្នកមាននាទីស៊ើបដំណឹង នឹងត្រួតត្រាហេតុការណ៍ផ្សេង ៗ ១២ នាក់គឺ តតោណ ១ តត្តណ ១ តតោតណ ១ នូជស ១ តេជស ១ តតោជស ១ សុរៈ ១–រាជៈ ១ សុរោរាជ ១ អរិដ្ឋៈ ១ នេមិ ១ អរិដ្ឋនេមិ ១ ។

កាលយក្សពួកនេះ បានដំណឹងហេតុការណ៍ផ្សេង ៗ មកហើយ ក៏ថ្លែងរំពងប្រាប់ដល់យក្សជាទ្វារបាល ១២ នាក់ទៀត ពួកទ្វារបាលទើបនាំដំណឹងនោះទៅ ក្រាបទូលដល់វេស្សវណ្ណមហារាជ ។

ព្រះបាទវេស្សវណ្ណមហារាជនោះ មានយក្សដែលជាសេនាបតី ២៨ នាក់ទៀតគឺ:

មាតលី ១ ចិត្តសេន, គន្ធព្វ, នឡោរាជ, ជនោសភ, សាតាគិរៈ, ហេមវត, បុណ្ណក, ករតិយ, គុល, សិវក, មុច្ចិន្ទ, វេស្សាមិត្ត, យុគន្ធរ, គោបាល, សុបគេធ, ហិរិ, នេត្តិ, មន្ទិយ,

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចាល, បន្ទ, អាឡវិក, បជ្ជិន្ទ, សុមុខ, មណិ, មាណិចរ, ទិឃ, សេរិសក, ។

ក្នុងវិសាណរាជធានី ទីប្រថាប់ របស់ព្រះបាទវេស្សវណ្ណមហារាជនោះ មានស្រះបោក្ខរណីមួយ ឈ្មោះស្រះធរណី មានសភាជាទីប្រជុំរបស់ពួកយក្ខមួយឈ្មោះភគលវតី ។

ស្រះបោក្ខរណី ដែលឈ្មោះថាធរណីនោះ ជាស្រះធំទូលាយបណ្ដោយ ៥០ យោជន៍ពេញប្រៀបទៅដោយទឹកជានិច្ច។

សភាដែលជាទីប្រជុំពួកយក្ខ ដែលមានឈ្មោះថា ភគលវតីនោះ តាំងនៅក្បែរស្រះនោះ ជាសភាធំផងហើយដោយកែវផ្សេងៗ ទទឹងនឹងបណ្ដោយប្រមាណ ១២ យោជន៍

ជុំវិញស្រះនោះ មានដើមឈើ ដែលមានផ្កានឹងផ្លែប្រចាំនៅជានិច្ច នឹងប្រកបដោយបក្សីផ្សេងៗ មានក្ងោកជាដើម ។

ពាហនៈ របស់ពួកយក្ខនោះមានច្រើនយ៉ាង គឺ គោ សត្វបំពាំមស្រ្តី បុរស ក្មេងស្រី ក្មេងប្រុស ពួកយក្ខដែលជាបរិវា

www.budinst.gov.kh www.elibraryofcambodia.org

របស់សេដ្ឋីណា ឡើងកាន់ពាហនៈទាំងនេះ ហើយជិះទៅក្នុងទីផ្សេងៗ មានបាលីអាងថា:

គាវឹ ឯកខុរំ កត្វា ពួកខ្លះប្រើគោជាពាហនៈ

បសុំ ឯកខុរ កត្វា ពួកខ្លះប្រើបសុសត្វជាពាហនៈ

ឥត្ថី វាហនំ កត្វា ពួកខ្លះប្រើស្ត្រីជាពាហនៈ

បុរិសំ វាហនំ កត្វា ពួកខ្លះក៏ប្រើបុរសជាពាហនៈ

កុមារឹ វាហនំ កត្វា ពួកខ្លះក៏ប្រើកុមារីជាពាហនៈ

កុមារំ វាហនំ កត្វា ពួកខ្លះប្រើកុមារជាពាហនៈ

តេ យានេ អភិរុហិត្វា សព្វា ទិសា អនុបរិយន្តិ គ្រាឡើងជិះយានពាហនៈទាំងនោះហើយ បរទៅកាន់ទិសទាំងពួងដូច្នេះ ។

ក្នុងយានពាហនៈទាំងនោះ សំរាប់យានគឺស្ត្រីនោះដោយច្រើនពួកយក្ខចូលចិត្តប្រើស្ត្រីដែលមានគភ៌ជាពាហន គេឡើងជិះលើខ្នងស្ត្រីដែលមានគភ៌នោះហើយទៅព្រោះខ្នងស្ត្រីមានគភ៌

www.budinst.gov.kh www.elibraryofcambodia.org

ជាខ្ទង់អែនជិះស្រួល បំណែកស្រ្តីដែលគ្មានគភ៌គេប្រើឲ្យអួសយានផ្សេងៗ ។

យានពាហនៈរបស់ព្រះបាទវេស្សវណ្ណ

ទិព្វយាន គឺយានដែលជាទិព្វរបស់វេស្សវណ្ណមហារាជនោះ មានច្រើនយ៉ាងគឺៈ ដំរី សេះ ប្រាសាទ វិហ៊ា ។

អធិប្បាយថាៈ វេស្សវណ្ណមហារាជនោះ ទ្រង់យានទាំងនោះ ស្តេចទៅតាមប្រាថ្នា ស្តេចទ្រង់ផ្ទឹកក្នុងព្រះដំណាក់លើប្រាសាទ ឬរាជយានដទៃ ៗ មានវិហ៊ាជាដើមហើយស្តេចទៅ ។

បុព្វកម្មរបស់វេស្សវណ្ណមហារាជ

កាលព្រះពុទ្ធជាម្ចាស់នៅមិនទាន់ឧប្បត្តិ មានព្រាហ្មណ៍ម្នាក់ឈ្មោះកុវេរព្រាហ្មណ៍ បានធ្វើគាបគាបអំពៅ ក្នុងរោងលក់ទឹកអំពៅ បានលើកទឹកអំពៅឲ្យទៅជាទាន ដល់មហាជនដែលដើរទៅមក រហូតពីរម៉ឺនឆ្នាំ គ្រាស្លាប់ហើយបានទៅកើតជាទេវបុត្រឈ្មោះកុវេរ នៅក្នុងជាន់ចាតុម្មហារាជិ

www.budinst.gov.kh www.elibraryofcambodia.org

កា គ្រាតមកបានសោយរាជ្យ ក្នុងរាជធានីឈ្មោះថា វិសាលា ទើបទ្រង់ព្រះនាមថា វេស្សវណ្ណ ។

ឋានសួគ៌ជាន់នេះ នៅក្នុងសេចក្តីគ្រប់គ្រងរបស់ឋានសួគ៌ជាន់តាវត្តិង្ស ។

ពណ៌នាឋានសួគ៌ជាន់តាវត្តិង្ស

ពាក្យថា តាវត្តិង្ស ប្រែថា ៣៣ ព្រោះឋានសួគ៌ជាន់នេះ មានទេវតាដែលជាប្រមុខ ៣៣ អង្គ ។ ដែលធំបំផុតជាព្រះរាជារបស់ទេពតាទាំងឡាយ ហៅថា "ព្រះឥន្ទ" តែពាក្យថា ព្រះឥន្ទនេះ ជាឈ្មោះដែលយើងធ្លាប់ហៅជាប់មាត់មក តាមឈ្មោះពិតមាន ៧ គឺៈ មឃវា, បុរិន្ទទោ, សក្កោ, វាសវោ, សហស្សក្ខោ, សុជម្បតិ, ទេវានមិន្ទោ ។

អធិប្បាយឈ្មោះព្រះឥន្ទទាំង ៧

១ - ដែលហៅថា មឃវា ព្រោះលោកកាលជាតិជាមនុស្សឈ្មោះមឃមាណព ។

www.budinst.gov.kh www.elibraryofcambodia.org

២ - ដែលហៅថា បុរិន្ទទោ ព្រោះលោកបានបំពេញទានក្នុងកាលមុន ។

៣ - ដែលហៅថា សក្កោ ព្រោះលោកបានបំពេញទានដោយគោរព ក្នុងកាលជាតិជាមនុស្ស ។

៤ - ដែលហៅថា វាសវោ ព្រោះលោកបានឲ្យទីសំណាក់អាស្រ័យជាទាន ដល់សាធារណជន ក្នុងកាលជាតិដែលជាមនុស្ស ។

៥ - ដែលហៅថា សហស្សក្ខោ ព្រោះលោកគិតហេតុផលបានមួយរំពេចទាំងពាន់បានគ្រប់យ៉ាង ។

៦ - ដែលហៅថា សុជម្បតិ ព្រោះលោកជាស្វាមីរបស់នាងសុជាតា

៧ - ដែលហៅថា ទេវានមិន្ទោ ឬ ឥន្ទ្រាធិរាជ ព្រោះលោកជាធំជាងទេវតាទាំងឡាយនូទាំងបាតុម និងតាវតឹង្ស ។

គុណធម៌ដែលឲ្យកើតជាព្រះឥន្ទ

គុណធម៌ដែលឲ្យកើតជាព្រះឥន្ទ មាន ៧ យ៉ាង ហៅថា

www.budinst.gov.kh www.elibraryofcambodia.org

វត្តបទ ៧ គឺៈ

១- មាតាបេត្តិភរោ ចិញ្ចឹមមាតាបិតារហូតអស់ជីវិត ។

២- កុលេជេដ្ឋាបចាយី គោរពកោតក្រែងច្បងក្នុងត្រកូល ។

៣- សណ្ហវាចា សំដីផ្អែមល្ហែមពីរោះជានិច្ច ។

៤- អបិសុណាវាចា មិននិយាយសិកសៀតបៀតបៀន

៥- វិគតមលមច្ឆេរោ មិនកំណាញ់ស្វិតស្វាញ ។

៦- សច្ចវាចា និយាយពិតជានិច្ច ។

៧- អកោធនោ មិនក្រេវក្រោធខឹងឃោឃៅ ។

ទេពតាជាន់តាវត្តិំង្សសរសើរព្រះឥន្ទ្រថា ជាសប្បុរស ដោយព្រះឥន្ទ្រ បានបំពេញធម៌ទាំង ៧ នេះទុក ក្នុងកាលជាតិជាមនុស្ស មានពុទ្ធភាសិតអាងថាៈ

មាតាបេត្តិភរំ ជន្តុំ កុលេជេដ្ឋាបចាយិនំ
សណ្ហំ សខិលសម្ភាសំ បេសុណេយ្យប្បហាយិនំ
មច្ឆេរវិនយេ យុត្តំ សច្ចំ កោធាភិភុំ នរំ
តំ វេ ទេវា តាវតិំសា អាហុ សប្បុរិសោ ឥតិ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រែថា នរជនណា ជាអ្នកចិញ្ចឹមមាតាបិតា ជាអ្នកមានសេចក្តីកោតក្រែងដល់អ្នកធំក្នុងត្រកូល ជាអ្នកពោលនូវពាក្យ ហ្មត់ចត់ស្រទន់ស្រទាប ជាអ្នកលះលែងនូវពាក្យញុះញង់ ជាអ្នកលះបង់នូវសេចក្តីកំណាញ់ ជាអ្នកទៀងទាត់ ជាអ្នកគ្រប សង្កត់នូវសេចក្តីក្រោធ ពួកទេវតានៅឋានត្រៃត្រឹង្សតែងហៅ នរជននោះឯងថាជា "សប្បុរស" ។

ព្រះឥន្ទជាធំនៅក្នុងឋានសួគ៌ជាន់តាវតឹង្ស ដែលមានទទឹង នឹងបណ្តោយដល់ម៉ឺនយោជន៍ មានប្រាសាទជំណាក់មួយកំពស់ ៧រយយោជន៍ ជាទីប្រថាប់របស់ព្រះឥន្ទ ។

មានឈើ ១ ដើមឈ្មោះ បារិច្ឆត្តកៈ មានលក្ខណៈទ្រង់ទ្រាយដូចឆ័ត្រ មានមណ្ឌល ៣ រយយោជន៍ ។

មានផែនសិលា ១ នៅក្រោមដើមនេះ ហៅថា បណ្ឌុកម្ពល ប្រវែង ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស ១៥ យោជន៍ មានពណ៌ដូចផ្កាច្បា ក្នុងវេលាដែលព្រះឥន្ទគង់

www.budinst.gov.kh www.elibraryofcambodia.org

ប្រថាប់ ក៏ទុំតផុតបុះទៅត្រឹមពាក់កណ្តាលអង្គ ក្នុងវេលាដែលព្រះឥន្ទក្រោកឡើង ក៏បោងឡើងដូចដើម ។

មានដំរី ១ ឈ្មោះ ឰរាវណ្ណ ដំរីនេះមិនមែនដំរីសត្វពិតទេព្រោះក្នុងទេវលោកមិនមានសត្វតិរច្ឆាន ដំរីនេះបានដល់ទេវបុត្រឈ្មោះ ឰរាវណ្ណ និមិត្តឡើង គឺក្នុងវេលាដែលព្រះឥន្ទស្តេចយាងប្រពាទឧទ្យាន ឰរាវណ្ណទេវបុត្រ ក៏និមិត្តខ្លួនជាដំរី កំពស់ ១៥០ យោជន៍ និមិត្តឲ្យជាក្បាល ៣៣ ក្បាលសំរាប់ទេវបុត្រ ៣៣ អង្គ ក្បាលមួយ ៗ វាស់ដោយជុំវិញ ៣០០ សិន ដោយបណ្តោយ ២០០ សិនក្នុងកណ្តាលក្បាលទាំង ៣៣ នោះមានក្បាលមួយ ៗ ៣០ យោជន៍ ឈ្មោះសុទស្សនៈ សម្រាប់ព្រះឥន្ទប្រថាប់ លើក្បាលនោះមានមណ្ឌបកែវ ១២ យោជន៍ ក្នុងរវាងក្បាលមួយ ៗ ដោតទៅដោយទង់ជ័យកំពស់ ១០០ យោជន៍ សុទ្ធតែសម្រេចដោយកែវ ៧ ប្រការ ទង់មួយ ៗ សឹងតែចងកណ្តឹងមាសវេលាត្រូវខ្យល់ ក៏ឮសំឡេងពីរោះ ដូចភ្លេងទិព្វ ក្នុងកណ្តាលមណ្ឌបមានបល្ល័ង្កកែវកំពស់ ១ យោជន៍ ព្រះឥន្ទប្រថាប់លើ

www.budinst.gov.kh www.elibraryofcambodia.org

បល្ល័ង្កនោះ បរិវារទេវបុត្រ ៣៣ អង្គ ក៏គង់លើបល្ល័ង្កកែវ ដែលនៅលើក្ងួបសម្រាប់ខ្លួន ក្នុងក្ងួបមួយ ៗ មានផ្ទៃង៧ ក្នុងផ្ទៃងមួយ ៗ ប្រវែង៥០យោជន៍ មានស្រះបោក្ខរណី ក្នុងផ្ទៃង ៧ ស្រះ ក្នុងស្រះបោក្ខរណីមួយមានឈូក ៧ ដើម ៗ មួយ ៗ មានផ្កា ៧ ផ្កាមួយ ៗ មាននាងទេពធីតា ឈរកាំ ៧ នាង ។ មានស្រះបោក្ខរណីមួយឈ្មោះស្រះនន្ទា ទទឹងនឹងបណ្តោយ ៥០០ យោជន៍ មានឧទ្យានមួយឈ្មោះចិត្តលតា ទទឹងនឹងបណ្តោយ ៥០០ យោជន៍ ក្នុងសួននេះជាទីកំសាន្តសប្បាយយ៉ាងលើសលន់ សម្រាប់ទេវតាជាន់តាវតឹង្ស ម្យ៉ាងទៀតពួកទេពតាដែលនឹងចុតិ ក្នុងគណៈដែលឃើញបុព្វនិមិត្តកើតឡើងក្នុងចិត្ត ថាខ្លួននឹងត្រូវចុតិ ហើយមានសេចក្តីសៅសោក តែបើបានទៅលេងក្នុងសួននោះហើយ ក៏ភ្លេចសោកភ្លេចស្លាប់ បានចុតិទៅយ៉ាងសប្បាយចិត្ត ។

ព្រះឥន្ទនោះ មានអគ្គមហេសី ៤ អង្គ គឺនាងសុជាតា សុធម្មា សុនន្ទា សុចិត្រា មាននាងស្នំ ២ កោដិកន្លះ ។

www.budinst.gov.kh www.elibraryofcambodia.org

ទិព្វសម្បត្តិរបស់ព្រះឥន្ទ ដូចដែលពណ៌នាមកនេះ កើតឡើងបានដោយសារអ្វី? ព្រះឥន្ទទ្រង់សាងឡើង ឬកើតឡើងឯង? លោកអ្នកអាចដឹងជ្រាបបាន ក្នុងកាលអានអតីតប្រវត្តិ របស់ព្រះឥន្ទដូចតទៅនេះ ។

អតីតប្រវត្តិរបស់ព្រះឥន្ទ (១)

កាលកន្លងទៅហើយ មានមាណពម្នាក់ឈ្មោះមឃៈ នៅក្នុងអចលគ្រាម ក្នុងដែនមគធៈ បានធ្វើទីដីមួយកន្លែងឲ្យរាបស្មើគួរជាទីរីករាយ មានមាណពដទៃទៀត បណ្ដេញគាត់ឲ្យចេញពីទីនោះ ហើយនៅដោយខ្លួនឯង ។ មឃៈមាណពមិនខឹងសោះ ហើយទៅធ្វើកន្លែងដទៃទៀត គេមកបណ្ដេញទៀត ទៅធ្វើកន្លែងដទៃទៀតជាច្រើនលើក ។

តមកខាងក្រោយ គាត់កាន់ចបទៅជម្រះកន្លែងមួយទំហំប៉ុនលានឲ្យរលីងស្អាត; ជនទាំងពួងតែងទៅកន្លែងនោះជានិច្ចក្នុងរដូវរងា មឃៈមាណពបំពក់ភ្លើងឲ្យ ក្នុងរដូវក្ដៅគាត់ដង

---

១ ជាក ធម្មបទដ្ឋកថា ភាគ ២ ទំព័រទី១៦៨

www.budinst.gov.kh www.elibraryofcambodia.org

ទឹកឲ្យ ។ តពីនោះមក មយ មាណពតែងចេញទៅពីព្រលឹម ធ្វើផ្លូវឲ្យរាបស្មើ នឹងផ្កាមែកឈើដែលគួរយកចេញ មាណព ឯទៀត ៗ មកសួរ គាត់ប្រាប់ថា ខ្ញុំធ្វើផ្លូវទៅឋានសួគ៌ ។ ទើបមាណពឯទៀតមកសូមធ្វើជាមួយផង បានគ្នាពីរនាក់ យូរ ៗ ទៅចូលម្តងម្នាក់ម្តងពីរនាក់ ចំពើនបានគ្នា ៣៣ នាក់ ធ្វើផ្លូវបានប្រហែល ២ យោជន៍ ។

គ្រានោះ គាមភោជក បានឃើញជនទាំងនោះធ្វើ ក៏គិតថា "មនុស្សទាំងនោះ ប្រកបកិច្ចការដែលមិនគួរប្រកប សោះ បើយកត្រីសាច់ជាដើមមកស៊ីផឹកស្រា ឬធ្វើកិច្ចដទៃក្រៅ ពីនេះវិញ សមជាអញនឹងបានកម្រៃបន្តិចបន្តួចមិនខាន" ទើប ឲ្យហៅមាណពទាំងនោះមកឃាត់មិនឲ្យធ្វើ ។ មាណពទាំង អស់នោះប្រកែកមិនព្រមឈប់ ។ គាមភោជកខឹងណាស់ ក៏ទៅក្រាបទូលមហាក្សត្រ ដោយពាក្យបង្កាច់ថា ខ្ញុំបាន ឃើញពួកចោរនៅក្នុងព្រៃ ។ ព្រះរាជាទ្រង់បង្គាប់ឲ្យទៅចាប់ មាណពទាំងនោះមក ។ គាមភោជក ក៏ចាប់នាំមកបង្ហាញថ្វាយ

www.budinst.gov.kh www.elibraryofcambodia.org

តាមព្រះរាជបញ្ជា ។ ព្រះរាជាមិនបានពិចារណាសោះ ស្រាប់តែទ្រង់បង្គាប់ឲ្យយកដំរីបញ្ជាន់អ្នកទាំងនោះ ។ ឯមឃៈមាណព បានឲ្យឱវាទដល់សំឡាញ់របស់ខ្លួនទាំងអស់ថា ចូរអ្នកទាំងឡាយតាំងចិត្តមេត្តាឲ្យល្អ គ្មានអ្វីជាទីពឹង ក្រៅពីមេត្តានេះទេ អ្នកទាំងឡាយកុំខឹងនឹងព្រះរាជា នឹងមេស្រុក នឹងដំរីសម្រាប់បញ្ជាន់ ឬ នឹងខ្លួនឯងឡើយ ៖ ចូរជាអ្នកមានចិត្តស្មើ ប្រកបដោយមេត្តាតែប៉ុណ្ណោះ ។ មាណពទាំងឡាយក៏ធ្វើតាម ។ ដោយអានុភាពនៃមេត្តាចិត្តរបស់ជនទាំងនោះ ដំរីក៏មិនហ៊ានទៅជិតឡើយ ។ ព្រះរាជាទ្រង់ជ្រាបដំណឹងនោះហើយ ទ្រង់មានព្រះរាជឱង្ការថា "ដំរីឃើញមនុស្សច្រើន បានជាមិនហ៊ានជាន់" ទើបទ្រង់បង្គាប់ឲ្យយកកន្ទេលមកគ្របជនទាំងនោះ ធ្វើដូច្នោះដំរីរឹតតែបែរឲ្យឆ្ងាយជាងមុនទៅទៀត ទើបទ្រង់ត្រាស់ហៅមាណពទាំងនោះមកសួរ តាំងអំពីហេតុដំបូងរៀងមក បានជ្រាបសព្វសេចក្ដីហើយ ក៏មានព្រះទ័យសោមនស្ស ទ្រង់ត្រាស់ថា "ម្នាលអ្នកទាំងឡាយ អម្បាលសត្វតិរច្ឆាន មេ្តចក៏

ដឹងគុណអ្នកទាំងឡាយ ប៉ុះអញជាមនុស្សត្រឡាំង ក៏មិនដឹងសោះ សូមអ្នកទាំងឡាយអត់ទោសផងចុះ" ហើយទ្រង់ឲ្យតាមភោជក ព្រមទាំងប្រពន្ធកូនទៅជាខ្ញុំបំរើមាណពទាំងនោះ ទ្រង់ព្រះរាជទានដីនោះទៅជាយានជំនិះ នឹងស្រុកនោះ ឲ្យជារបស់មាណពទាំងឡាយនៅតាមសប្បាយ ។ មាណពទាំងឡាយ មានសេចក្ដីរីករាយ ដោយគំនិតថា "អានិសង្សបុណ្យយើងបានឃើញហើយ" ទើបប្រឹក្សាគ្នាថា ឥឡូវនេះ គួរតែយើងធ្វើបុណ្យឲ្យក្រៃលែងតទៅទៀត" លុះយល់ព្រមគ្នាហើយក៏ឲ្យហៅជាងឈើមក ឲ្យធ្វើសាលាសំណាក់ ត្រង់ផ្លូវក្រឡែងកែងមួយអន្លើ មិនឲ្យពួកស្រី ៗ ចូលធ្វើជាមួយផងឡើយ ។

ឯមឃមាណព មានប្រពន្ធ ៤ នាក់គឺ នាងសុធម្មា ១ សុនន្ទា ១ សុចិត្តា ១ សុជាតា ១ ។ នាងសុធម្មា ត្រូវគំនិតគ្នានឹងជាងឈើ នាងឲ្យសំណូកជាងឈើហើយនិយាយថា ត្រូវអ្នកឯងធ្វើឲ្យខ្ញុំបានជាធំក្នុងសាលានេះកុំខាន ។ ជាងឈើយល់ព្រមតាមហើយ ក៏ហាលឈើសម្រាប់ធ្វើហោជាងឲ្យស្ងួត

www.budinst.gov.kh www.elibraryofcambodia.org

ឈ្លួសសំអាតស្រេចហើយ ឆ្លាក់អក្សរថា "នេះសាលាសុធម្មា" ហើយក៏រុំដោយសំពត់លាក់ទុកនៅផ្ទះនាងសុធម្មា ។ លុះដល់ពេលាធ្វើសាលាហើយស្រេច ត្រូវលើកហោជាងក៏និយាយតើធ្វើជាភ្លេច មិនបានធ្វើហោជាង ហើយត្អូញត្អែរថា លុះតែបានហោជាង ដែលគេធ្វើរួចស្រេចពីមុនមកទើបស្រួល ។ មាណពទាំងឡាយសួរថាឥឡូវនេះ យើងត្រូវធ្វើដូចម្ដេច? ជាងឈើថា យើងត្រូវរកហោជាងដែលគេធ្វើទុកលក់ស្រាប់ៗ ។ មាណពទាំងនោះ បានឃើញហោជាងនៅផ្ទះនាងសុធម្មា ក៏និយាយទិញឲ្យថ្លៃ ១ ពាន់កហាបណៈ ។ នាងសុធម្មា មិនព្រមលក់សោះ បែរនិយាយថា បើអ្នកទាំងអស់ឲ្យខ្ញុំបានបំណែកបុណ្យក្នុងសាលានេះផង ខ្ញុំមិនយកថ្លៃទេ ។ ជាងឈើជួយជម្រុលថា លោកម្ចាស់អើយ ហានដំទៃ លើកតែព្រហ្មលោកចេញគ្មានហានណាឥតមាតុគ្រាមទេ សូមលោកយកហោជាងនេះចុះ ខ្ញុំបាទនឹងធ្វើការឲ្យបានសម្រេចឆាប់ ។ មាណពទាំងនោះក៏ព្រមយកហោជាងនោះមកឲ្យជាងធ្វើ សាលាស្រេចហើយ

www.budinst.gov.kh www.elibraryofcambodia.org

ទិណ្ឌជា ៣ ចំណែកគឺៈ ១ ចំណែកសម្រាប់អ្នកធំ ១ ចំណែកសម្រាប់មនុស្សទុគ៌ត ១ ចំណែកសម្រាប់មនុស្សមានជម្ងឺ ។ ជនទាំង ៣៣ នាក់នោះ ក្រាលផែនក្ដារ ៣៣ បន្ទះ ១ បន្ទះម្នាក់ ៗ ហើយឲ្យសញ្ញាដល់ដំរីថា អាគន្តុកៈមកអង្គុយលើផែនក្ដារនរណា ត្រូវឯងនាំទៅ ប្រគល់ឲ្យដល់ម្ចាស់ក្ដារនោះ ការគក់ប្រាប់នឹងម្ហូបចំណីគ្រប់យ៉ាងជាភារៈរបស់អ្នកម្ចាស់ក្ដារនោះទាំងអស់ ។ ដំរីក៏ធ្វើតាមដូច្នោះ ។ ឯមឃៈមាណពបានដាំដើមរលួសផ្គង ១ ដើមនៅក្បែរសាលា ហើយក្រាលផែនថ្មប្រុបគល់រលួសផ្គងនោះ ។ អ្នកផងដែលចូលទៅជិតសាលានោះតែបានក្រឡេកមើលទៅហោជាង តែងអានអក្សរនិយាយគ្នាថា សាលាសុធម្មា ៗ ត្រង់ឈ្មោះមនុស្សទាំង ៣៣ នាក់នោះ មិនប្រាកដសោះ ។

ឯនាងសុនន្ទាគិតថា "មាណពទាំងនេះ កាលកសាងសាលាមិនឲ្យចំណែកបុណ្យដល់អញផងឡើយ នាងសុធម្មាជាស្រីឆ្លាតបានហោជាង ទើបបានចំណែកបុណ្យក្នុងសាលានេះ អញបើធ្វើអ្វីមួយនឹងគេទើបគួរ តើអញធ្វើអ្វីអេះ? ទើបនាង

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យជីកស្រះបោក្ខរណីមួយនៅក្បែរសាលានោះ មានឈ្មោះប្រាកដថា "សុនន្ទាបោក្ខរណី" ។ ឯនាងសុចិត្តា បានធ្វើសួនផ្កា ១ ជារមណីយដ្ឋាន ជាទីគួររីករាយ បុប្ផាផលទាំងឡាយមានគ្រប់គ្រាន់ មានឈ្មោះប្រាកដថា "សុចិត្តលតាវន" សម្រាប់មហាជនកំសាន្តចិត្ត " ឯនាងសុជាតា គិតថា "អញចាំបាច់ធ្វើអ្វីទៀត ព្រោះអញជាធីតារបស់ឪពុកធំមឃមាណព ហើយជាប្រពន្ធរបស់មឃមាណពនេះស្រាប់ គាត់ធ្វើអ្វីនោះឯងឈ្មោះថាអញធ្វើដែរ" ហើយក៏ចំតែស្អិតស្អាងអត្តភាពខ្លួនឯងប៉ុណ្ណោះ ។

ក្នុងវេលាដែលជនពួកនោះមរណកាលហើយ បានឡើងទៅកើតជាទេវបុត្រទេវធីតា ក្នុងតាវតិំសទេវលោក ជាងដែលទទួលភារធ្វើសាលា បានឡើងទៅកើតជាវិស្សុកម្មទេវបុត្រ។

ឋានតាវតិំសនោះ ពីដើមពួកអសុរនៅ ក្នុងខណៈដែលពួកព្រះឥន្ទកើតឡើងថ្មី ពួកអសុរបានចាត់ការទទួលយាងអ៊ុកៈធឹក មានការលៀងទឹកទិព្វព្រះឥន្ទបានឲ្យសញ្ញាដល់បរិស័ទ

www.budinst.gov.kh www.elibraryofcambodia.org

របស់ព្រះអង្គ ដើម្បីមិនឲ្យនរណា ៗ ផឹក បំណែកពួកអសុរនាំគ្នាផឹកទឹកទិព្វ ហើយក៏ស្រវឹងដួលដេកទាំងអស់គ្នា ។

## ទឹកទិព្វក្នុងតាវតឹង្ស

ទឹកទិព្វដែលពួកអសុរផឹកនោះ កើតអំពីវល្លិឈើ មួយវល្លិឈើនោះហៅថាវល្លិរភាំង កើតឡើងក្នុងសួនចិត្តលតា ។

គឺក្នុងតាវតឹង្សទេវលោក មានវល្លិឈើ ដុះនៅក្នុងសួនចិត្តលតា មានទឹកទិព្វកើតឡើងក្នុងផ្លែវល្លិឈើនោះ ពួកទេវតាផឹក ល្មមត្រឹមតែម្តង ក៏ស្រវឹងដួលដេកនៅនឹងទីដេក-ទិព្វដល់ ៤ ខែ ។ វល្លិឈើនោះ ដែលនឹងមានផ្លែទៀត ក៏យូររាប់ទាំងពាន់ឆ្នាំ(១) ពួកទេវតាដែលជាអ្នកផឹកសុរា ក៏នាំគ្នាឃ្លាន តែស៊ូអត់ដោយសង្ឃឹមថា មិនយូរគង់នឹងបានផឹក ហើយក៏នាំគ្នាទៅមើលវល្លិឈើនោះ ទាល់តែមានផ្លែ ដោយហេតុនេះ ទើបហៅវល្លិឈើនោះថា វល្លិរភាំង ។ កាលពួកអសុរដួលដេកស្រវឹងមិនដឹងខ្លួនហើយ ព្រះឥន្ទ្រទ្រង់ត្រិះរិះថា

---

១ ពាក្យថាពាន់ឆ្នាំ គឺរាប់យកឆ្នាំក្នុងមនុស្សលោក មិនមែនឆ្នាំក្នុងឋានសួគ៌ ។

www.budinst.gov.kh www.elibraryofcambodia.org

អាត្មាអញមិនគួរនឹងសោយរាជ្យនៅប្រឡូកប្រឡល់ ជាមួយពួកអ្នកប្រមឹកនេះឡើយ ហើយឲ្យសញ្ញាដល់ពួកបរិវារ នាំគ្នាចាប់ទេវតាប្រមឹកបោះចុះទៅក្នុងមហា សមុទ្រ ទេវតាពួកនោះបានធ្លាក់ចុះទៅក្នុងមហា សមុទ្រទាំងអស់ តែដោយបុញ្ញានុភាពរបស់ទេវតាពួកនោះ បានមានអសុរវិមានកើតឡើងក្រោមភ្នំសិនេរុ នឹងមានដើមចិត្តបាតលី កើតឡើងផង ។ កាលព្រះឥន្ទ្រកំចាត់ពួកទេវតាប្រមឹកបានហើយ ក៏មានទេវតានគរឈ្មោះតាវតិំស្ស ដែលមានទំហំ ១ ម៉ឺនយោជន៍កើតឡើងប្រដាប់ដោយសួននឹងស្រះគួររីករាយ ។

ក្នុងកណ្ដាលព្រះនគរ មានប្រាសាទដ៏ណាក់មួយឈ្មោះវេជយន្តប្រាសាទប្រតិស្ឋាននៅ វេជយន្តប្រាសាទនោះ សម្រេចដោយកែវ ៧ ប្រការ កំពស់ ៨០០ យោជន៍ ដោតទៅដោយទង់កំពស់ ៣០០ យោជន៍ ទង់មួយ ៗ មានដងនឹងតួទង់ផ្សេង ៗ គ្នា គឺបើដងមាស ទង់កែវមណី ដងកែវមណី ទង់មាស ដងកែវពពាឡ ទង់កែវមុក្ដា ដងកែវ ៧ ប្រការ ទង់កែវ ៧ ប្រការ

www.budinst.gov.kh www.elibraryofcambodia.org

ទង់ដែលតាំងនៅក្នុងកណ្ដាល កំពស់ ៣០០ យោជន៍ វេជ-យន្តប្រាសាទនោះកើតឡើង សម្រាប់ព្រះឥន្ទដោយផលសាងសាលា ។

ផលដែលដាំដើមរលួសផ្អុង បណ្ដាលឲ្យដើមបារិឆត្តកៈដែលមានមណ្ឌល ៣០០ យោជន៍កើតឡើង ។

ផលដែលបាត់ផែនឬទុកឲ្យមនុស្សអង្គុយក្រោមដើមរលួសផ្អុង ធ្វើឲ្យមានបណ្ឌុកម្ពលសិលា ដែលមានប្រមាណបណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ មានពណ៌បីដូចជាពណ៌នៃផ្កាច្បា កើតឡើងសម្រាប់ជាទីប្រថាប់របស់ព្រះឥន្ទ ក្នុងវេលាស្ដេចយាងមកប្រជុំ ។

ដំរីដែលសម្រាប់ដឹកនាំគ្រឿងទព្វសម្ភារសាងសាលានឹងទទួលបំរើក្នុងការនាំមនុស្សមកដាក់សាលា ទៅឲ្យម្ចាស់របស់បានកើតជាទេវបុត្រឈ្មោះ ឰរាវណ្ណទេវបុត្រ ដែលបាននិមិត្តជាដំរីឰរាវណ្ណដូចពោលហើយខាងដើម ។

www.budinst.gov.kh www.elibraryofcambodia.org

បំណែកខាងនាងសុធម្មា បានកើតជាមហេសីរបស់ព្រះឥន្ទ្រ នឹងមានទេវសភា ទទឹងនឹងបណ្ដោយ ៥០០ យោជន៍ ឈ្មោះសុធម្មាទេវសភា កើតឡើងដោយបុណ្យរបស់នាង ។

នាងសុនន្ទា ក៏បានកើតជាមហេសីព្រះឥន្ទ្រដូចគ្នា នឹងមានស្រះនន្ទាបោក្ខរណី ទទឹងនឹងបណ្ដោយ ៥០០ យោជន៍ កើតឡើងដោយបុណ្យរបស់នាង ។

នាងសុចិត្រា ក៏បានកើតជាមហេសីរបស់ព្រះឥន្ទ្រដែរ នឹងមានសួនចិត្តលតា ទទឹងនឹងបណ្ដោយ ៥០០ យោជន៍ កើតឡើងដោយបុណ្យរបស់នាងដូចគ្នា ។

## ប្រវត្តិនាងសុជាតា

បំណែកនាងសុជាតា បានកើតជាកុកញីនៅប្រកភ្នំមួយកាលព្រះឥន្ទ្រទតព្រះនេត្រពួកនាងបំរើ ក៏ឃើញថានាងទាំង ៣ បានកើតនៅក្នុងសំណាក់ព្រះអង្គហើយ មិនឃើញតែនាងសុជាតា កាលសំឡឹងមើលដោយទិព្វនេត្រ ក៏ទ្រង់ឃើញថានាងសុជាតា បានទៅកើតក្នុងកំណើតកុក ទើបទ្រង់ថ្លែងភេទទៅនាំនាងកុក

www.budinst.gov.kh www.elibraryofcambodia.org

ឡើងទៅកាន់តាវតិង្ស ទ្រង់លែងទុកនៅមាត់ស្រះ ហើយសេចទៅប្រាប់នាងទាំង ៣ ឲ្យទៅមើល កាលនាងទាំង ៣ បានឃើញក៏នាំគ្នាជៀមជាមឲ្យដោយអាការផ្សេងៗ នាងកុកដឹងខ្លួនមានសេចក្តីអៀនខ្មាសជាច្រើនព្រោះរលឹកជាតិដែលកន្លងមក ហើយបានកាលនាងទាំង ៣ ត្រឡប់ទៅវិញ ព្រះឥន្ទ្រក៏ស្តេចទៅនាំនាងកុកចុះទៅកាន់ប្រកន្សំវិញ ហើយត្រាស់សួរថា: បង់ទៅនៅនឹងភឿនរបស់នាងឬ? កាលនាងកុកតបថាចង់ទៅ ក៏ទ្រង់ប្រៀនប្រដៅឲ្យរក្សាសីល ៥ នាងកុកក៏ត្រេកអរធ្វើតាម ចាប់តាំងអំពីរក្សាសីល ៥ ហើយ ក៏ដើររកស៊ីតែត្រី សត្វស្លាប់ បានខ្លះមិនបានខ្លះ មិនយូរប៉ុន្មានរាងកាយរបស់នាងកុកក៏ស្គាំងស្គមទ្រោមទ្រុឌ ទីបំផុតក៏ដល់នូវសេចក្តីស្លាប់ ដោយសេចក្តីអត់ឃ្លាន ។

កាលស្លាប់ហើយ បានទៅកើតជាកូនជាងជម្សាញ ក្នុងក្រុងពារាណសីដោយផលដែលរក្សាសីល ៥ នោះ ក្នុងវេលាមានអាយុបាន ១៥-១៦ ឆ្នាំ ព្រះឥន្ទ្រទើបទ្រង់ជ្រាប នឹងបានជំណែងភេទជាបុរសម្នាក់ បររទេះផ្ទុកពេញទៅដោយកែវ ៧



www.budinst.gov.kh www.elibraryofcambodia.org

ប្រការដែលព្រះអង្គទ្រង់បណ្តាលឲ្យប្រាកដ ឃើញដល់ភ្នែកជនទូទៅក្នុងក្រុងពារាណសី កាលមានមនុស្សសួមទិញ ក៏ប្រាប់ថា នឹងលក់ឲ្យដល់អ្នកស្រីដែលរក្សាសីល ក៏បរទៅតាមថ្នល់តូចថ្នល់ធំ ក៏មិនបានឃើញស្រីណាដែលរក្សាសីល មានតែអ្នកសួរថា សីលបានដល់អ្វី? ជារូប ស ខ្មៅ ខៀវ លឿង យ៉ាងណា? ព្រះឥន្ទក៏មិនតប ក្នុងគណៈនោះមានស្រីម្នាក់ប្រាប់ថា កូនក្រមុំរបស់ជាងដម្បាញម្នាក់ នៅក្នុងថ្នល់ខាងមុខនោះ គេប្រាប់ថាគេរក្សាសីល ព្រះឥន្ទក៏សំដៅទៅដល់ហើយ ក៏ទ្រង់ណែនាំឲ្យនាងស្គាល់ព្រះអង្គតាមសេចក្តីពិត នឹងបានប្រគល់កែវ ៧ ប្រការឲ្យ នឹងប្រៀនប្រដៅឲ្យរក្សាសីល ៥ ឲ្យបានជរាបអស់ជីវិត ។

គ្រានាង ស្លាប់ចាកជាតិនោះហើយ បានទៅកើតជារាជបុត្រីនៃព្រះបាទវេបចិត្តិអសុរិន្ទ ក្នុងពិភពអសុរ ជាអ្នកមានរូបរាងល្អក្រៃលែង មានពណ៌ដូចជាមាសដោយអំណាចរក្សាសីល ៥ ដល់ពីរជាតិ ។

www.budinst.gov.kh www.elibraryofcambodia.org

បំណែកព្រះបាទវេបចិត្តិអសុរិន្ទជាព្រះរាជបិតាមិនព្រម លើកនាងឲ្យដល់អសុរដែលមកសូម សូម្បីតែម្នាក់ឡើយ ដោយអាងថា នឹងឲ្យបិតាពីសមើលខ្លួនឯងហើយប្រកាសឲ្យប្រជុំពួកអសុរទាំងអស់ មានបង្គាប់ឲ្យនាងយកភួងមាល័យ ទៅបំពាក់អ្នកណា ដែលនាងពេញចិត្ត ។

ព្រះឥន្ទទៅទទួលនាងសុជាតាធ្វើមហេសី

លំដាប់នោះព្រះឥន្ទទ្រង់ជ្រាបដោយទិព្វនេត្រ ទើបស្ដេចជំណែងភេទជាអសុរចាស់ ចុះទៅអង្គុយខាងក្រៅជំនុំ (ក្រៅវង់) កាលនាងសុជាតាមើលឃើញ ក៏កើតសេចក្ដីស្រឡាញ់យ៉ាងក្លៀវក្លា ដោយអំណាចបុព្វេសន្និវាស ទើបបោះភួងមាល័យទៅឲ្យ ហើយពោលថា នុះជាស្វាមីរបស់យើង ពួកអសុរដែលប្រជុំនៅក្នុងទីនោះក៏នឹកអៀនចិត្តថា បុត្រីម្ចាស់នាយរបស់ខ្លួនបានប្ដីចាស់ជាងតារបស់ខ្លួនឯងទៅទៀត ។

បំណែកព្រះឥន្ទក៏សំដៅទៅចាប់ត្រកងនាងសុជាតាហើយបញ្ចេញវាចាថា "ខ្លួនយើងជាអមរិន្ទឥន្ទ្រាធិរាជ" គ្រាប្រ-

www.budinst.gov.kh www.elibraryofcambodia.org

កាសយ៉ាងនេះហើយ បានតាំងនាងហោះទៅកាន់អាកាស កាលពួកអសុរដឹងដូច្នោះ ក៏នាំគ្នាជាប់តាមទៅដោយសេចក្ដីក្រោធ ចំណែកព្រះឥន្ទ្រ គ្រាហោះទៅដល់រវាងកណ្ដាលផ្លូវ ក៏ដល់វេជយន្តរថ ដែលព្រះមាតលីនាំទៅចាំទទួលព្រះអង្គ ព្រះឥន្ទ្រនាំនាងស្ដេចឡើងរថហើយ បែរព្រះភក្ត្រឆ្ពោះទៅកាន់ទេពនគរនាផ្លូវព្រៃរកា ដែលជាទីនៅរបស់ពួកគ្រុឌ ពួកកូនគ្រុឌបានឮសំឡេងរថ ក៏នាំគ្នាស្រែកបេកបាចឡើងដោយសេចក្ដីខ្លាច ព្រះឥន្ទ្រទ្រង់យល់ថា បើនឹងទៅតាមផ្លូវនោះ បណ្ដាកូនគ្រុឌមុខជានឹងវិនាសអស់ ទើបបង្គាប់ឲ្យត្រឡប់រថ ព្រះមាតលីតឿនសេះសន្ធព្វទាំង ៣ ជាន់ឲ្យត្រឡប់ ។ ពួកអសុរឃើញព្រះឥន្ទ្រត្រឡប់ក៏ចូលចិត្តថា មានអ្នកជួយភ័យខ្លាចនឹងស៊ូរមិនបាន បានព្រមគ្នាថយត្រឡប់ចូលក្រុងអសុរដោយរហ័ស ចំណែកព្រះឥន្ទ្រកាលត្រឡប់ទៅដល់ផ្លូវបែក ក៏បានស្ដេចទៅកាន់ទេពនគរដោយសុវត្ថិភាព ។

www.budinst.gov.kh www.elibraryofcambodia.org

ត្រាទៅដល់ហើយ បានទ្រង់តាំងនាងសុជាតា ដែលជាធិតាអសុរ ទុកក្នុងដំណែងជាធំជាងទេពអប្សរ ពីរកោដិកន្លះនាងសុជាតាបានទូលសូមពរទុកថា បើព្រះឥន្ទនឹងស្ដេចយាងទៅណា សូមបានប្រោសឲ្យនាងទៅផង ដោយអាងថានាង មិនមានមាតាបិតា នឹងបងប្អូននៅក្នុងទេវលោកឡើយ ព្រះឥន្ទទ្រង់អនុញ្ញាតឲ្យតាមដែលនាងសូមនោះ គ្រប់ប្រការ ។

ចាប់ដើមតាំងអំពីនោះមក កាលដើមបិត្តបាតលីបេញផ្កា ពួកអសុរនឹកដល់ដើមបារិឆត្តកៈក្នុងតាវតិំង្ស ហើយបានត្រៀមលើកទ័ពឡើងទៅច្បាំងនឹងព្រះឥន្ទ ក្នុងរយៈផ្លូវអំពីពិភពអសុរទៅកាន់តាវតិំង្សនោះ ព្រះឥន្ទបានតាំងទ័ពទុក ៥ កន្លែង គឺទីលើទឹកមហាសមុទ្ទ ជាទ័ពនាគ តអំពីនោះជាទ័ពគ្រុឌ ទ័ពកុម្ភណ្ឌ ទ័ពយក្ស ទ័ពមហារាជទាំង ៤ ទីទ្វារតាវតិំង្ស ព្រះឥន្ទបាននិម្មិតរូបព្រះឥន្ទ កាន់ព្រះខ័នពេជ្រគ្រប់ទ្វារ កាលទ័ពអសុរវាយទ័ពទាំង៥ កន្លែងជាលំដាប់ ចូលទៅដល់ទ្វារតាវតិំង្សទេពនគរហើយ បានឃើញរូបព្រះឥន្ទ ក៏នាំគ្នាភ័យខ្លាច ដក

www.budinst.gov.kh www.elibraryofcambodia.org

ទំព្យថយត្រឡប់ទៅវិញ ដោយចូលបិត្តថា ព្រះឥន្ទបេញច្បាំង ដោយព្រះអង្គឯង ។

បប់សត្ថកបា ភាគទី ១

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org